Reading Book

ពិភពរឿងនិទាន

The World of Stories



# ធនញ្ជ័យកុមារ

# THUN CHEY KOMA

សៀវភៅជាឃ្លាំងនៃចំណេះដឹង

Books are the source of knowledge



កាលដើមឡើយមានប្ដីប្រពន្ធពីរនាក់។ នៅរាត្រីមួយ នាងជាប្រពន្ធបានយល់សប្តិឃើញថា "បេះដូង បេះបានទាំងផ្លែ យល់សប្តិឃើញខែៗរះពេញបូណ៌មី"។ លុះនាងភ្ញាក់ឡើងចាំជាក់ក្នុងសុបិន នាងក៏ដើរទៅផ្ទះតាហោរ តែអ្នកហោរមិននៅៗតែប្រពន្ធនាងប្រាប់ប្រពន្ធតាហោរនូវសុបិនរបស់ខ្លួន។ ប្រពន្ធតាហោរយល់ឃើញថា "នាងនឹងកើតបានកូនប្រុសមួយ ហើយកូននោះនឹងក្លាយជាលោកធំ" តែប្រពន្ធតាហោរមិនប្រាប់ដូច្នេះទេ បែរជាប្រាប់នាងថា "កូននេះកើតមកនឹងទៅជាខ្ញុំគេ" នាងស្ដាប់ហើយក៏ត្រលប់ទៅផ្ទះវិញ។

លុះនាងគ្រប់ខែ នាងសម្រាលបានកូនប្រុសមួយគួរជាទីស្រឡាញ់ ហើយដាក់ឈ្មោះថា **ធនញ្ជ័យ**។ ដល់ពេល **ធនញ្ជ័យ** មានអាយុ៧ឆ្នាំ គេតែងតែដើរលេងនៅមុខផ្ទះសេដ្ឋីរាល់ថ្ងៃ។ ឯប្រពន្ធសេដ្ឋីកំពុងត្បាញនៅលើផ្ទះក៏ធ្លាក់គ្រាប់ត្រល់ទៅលើដី ហើយស្រែកប្រើ **ធនញ្ជ័យ** ថា "អាជ័យហ្អា៎! រើសត្រល់ឱ្យអញបន្តិច" **ធនញ្ជ័យ** សួរថា "បើខ្ញុំរើសឱ្យ តើមានអ្វីឱ្យមកខ្ញុំ" ប្រពន្ធសេដ្ឋីប្រាប់ថា "អញឱ្យអំបុកឯងចុះ"។ ទើប **ធនញ្ជ័យ** រើសត្រល់ឱ្យគាត់ ហើយ **ធនញ្ជ័យ** អង្គុយចាំយកអំបុកពីប្រពន្ធសេដ្ឋី។ ប្រពន្ធសេដ្ឋីឱ្យអំបុកមួយកញ្ជើទៅ**ធនញ្ជ័យ**។ តែ **ធនញ្ជ័យ**ប្រកែកថា "អំបុកប៉ុណ្ណឹងខ្ញុំមិនយកទេ" ប្រពន្ធសេដ្ឋីលួង **ធនញ្ជ័យ** ថា "អាជ័យហ្អា៎! អំបុកនេះច្រើន ណាស់ណា៎"។ **ធនញ្ជ័យ** កាន់តែខឹងយំទារអំបុកថែមទៀត។

Once upon a time, there lived a couple. One night the wife dreamt that she could pick the whole bunch of coconuts and saw a full moon. When she got up in the morning, she walked toward a fortune-teller's house, but he was not at home; so the woman told the fortune-teller's wife about her dream. The fortune-teller's wife thought that the woman would have a baby boy, and the child would become a dignitary. Instead of telling the woman the truth, she told her that the baby boy would become a servant. After learning this bad news, she returned home. When the time of birth delivery had come, she gave a birth to a lovely baby boy, and he was named THUN CHEY. When THUN CHEY was 7 years old, he always went to play around a wealthy official's residence. One day, while the official's wife was weaving in the house, a shuttle dropped on the ground, and she called to THUN CHEY, 'CHEY! Pick the shuttle for me.' 'If I pick it for you, what will you give me?' asked THUN CHEY. 'I will give you pounded rice,' the official's wife replied. So, THUN CHEY picked the shuttle for her, and he waited for pounded rice from the official's wife, who offered him a basket of it. But THUN CHEY denied, 'I will not take this little amount of pounded rice.' 'CHEY! The pounded rice is a lot already,' she consoled him. But Thun Chey became even more furious, demanding more pounded rice.



សេដ្ឋីឃើញ **ធនញ្ជ័យ** យំដូច្នេះ ក៏ដើរចូលមកមើលសួរថា "អាជ័យ! ហេតុអ្វីបានជាឯងយំ" ប្រពន្ធប្រាប់ប្តីថា "ខ្ញុំប្រើវាឱ្យរើសត្រល់ ខ្ញុំថានឹងឱ្យអំបុកទៅវា ឥឡូវខ្ញុំឱ្យអំបុកវាមួយកញ្ជើហើយ វានៅតែមិនព្រមយកទៀត"។ ពេលនោះសេដ្ឋីនិយាយថា "ឯងមិនដឹងចិត្តអាជ័យទេហ្អី ទុកឱ្យខ្ញុំវិញ"។ សេដ្ឋីចាក់អំបុកចូលចង្អេរកៀរឱ្យពេញ និងចាក់អំបុកពេញក្នុងកញ្ជើ ទើបហៅ **ធនញ្ជ័យ** មកជិតសួរថា "អាជ័យមកណេះ! អំបុកពីរហ្នឹងឯងយកមួយណា?" **ធនញ្ជ័យ** ចង្អុលយកអំបុកក្នុងចង្អេរ ព្រោះមានអំបុកពេញហើយធំទៀតផង។ ពេលនោះ **ធនញ្ជ័យ** ភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលដែលវាចាក់អំបុកដាក់ក្នុងបង្វេច វាក៏គិតក្នុងចិត្តថា "អញចាញ់បោកសេដ្ឋីនេះហើយ អញនឹងផ្ចាញ់ប្រាជ្ញាគាត់ឱ្យបាន ទើបអញសុខចិត្ត"។

The official heard the argument and went in and asked, 'CHEY! Why are you weeping?' His wife said, 'I asked him to pick the shuttle for me, promising to give him pounded rice. Now I give him the rice, but he refuses to accept it.' Suddenly, the official said, 'You don't know CHEY's heart! Let me deal with him.' Then, the official poured pounded rice into a flatten basket, spreading it as big as can be seen. Also, he poured pounded rice into another bowl-shaped basket and called THUN CHEY to come. 'CHEY, come here! Which basket will you choose, the bowl-shaped basket or the flatten one?' he asked. CHEY pointed to the flatten basket which was full of pounded rice and it looks a lot. However, THUN CHEY was upset when he poured the pounded rice into his bag. 'I am tricked by the official. I will outwit him to my heart's content.' Chey said to himself.



**ធនញ្ជ័យ** ដើរទៅដល់ផ្ទះ និយាយជាមួយនឹងពុកម្ដាយថា "លោកពុក អ្នកម៉ែ ខ្ញុំចង់ទៅនៅបម្រើលោកសេដ្ឋី" ម្ដាយស្ដាប់កូនហើយក៏និយាយនឹងកូនថា "កូនមាសម្ដាយ ម្ដាយមិនមានជំពាក់បំណុលសេដ្ឋីនោះទេ ឱ្យម្ដាយយកកូនទៅនៅជាខ្ញុំគេម្ដេចនឹងកើតទៅ" **ធនញ្ជ័យ** ប្រាប់ម្ដាយថា "ខ្ញុំទៅនៅគ្រាន់តែចង់ផ្ចាញ់ប្រាជ្ញាគាត់តែប៉ុណ្ណោះទេណាម៉ែ!" ម្ដាយក៏ឱ្យកូនទៅនៅជាខ្ញុំសេដ្ឋីចាប់ពីថ្ងៃនោះឯង។ រាល់ព្រឹកសេដ្ឋីប្រើ **ធនញ្ជ័យ** ឱ្យកាន់ថង់ស្លាដើរតាមក្រោយធ្វើដំណើរទៅរាជរោង។ ឯ**ធនញ្ជ័យ** ដើរក្រដល់ត្បិតសេដ្ឋីជិះសេះដើរមិនទាន់ឡើយ។ សេដ្ឋីស្រដីថា "អាជ័យ! ឯងដើរដូចម្ដេចបានជាមិនទាន់អញអីចឹង?" **ធនញ្ជ័យ** ថា "ត្បិតខ្ញុំខ្លាចជ្រុះប្រអប់ស្លា" ទើបសេដ្ឋីថា "ឯងដើរឱ្យទាន់អញមកមិនបាច់ខ្លាចជ្រុះទេ" **ធនញ្ជ័យ** ស្ដាប់ហើយឆ្លើយថា បាទ។ លុះថ្ងៃក្រោយមកទៀត សេដ្ឋីឡើងជិះសេះដូចសព្វដង **ធនញ្ជ័យ** ក៏ធ្វើជាជ្រុះប្រអប់ស្លាអស់ពីថង់។ ពេលទៅដល់សាលា សេដ្ឋី ចុះពីលើខ្នងសេះឡើងទៅជួបជុំអស់នាហ្មឺនតូចធំ ហើយហៅ **ធនញ្ជ័យ** យកប្រអប់ស្លាមកហូប។ ឯ **ធនញ្ជ័យ** យកថង់ស្លាជូនសេដ្ឋីហើយក៏ថយមកអង្គុយនៅកន្លែងមួយដ៏សមគួរ។ សេដ្ឋីឃើញតែថង់ទទេក៏ខ្មាសគេមិនហ៊ាននិយាយស្ដី។ លុះដល់ពេលត្រលប់ទៅផ្ទះវិញ ហៅ **ធនញ្ជ័យ** មកជិតសួរថា "អាជ័យ! ម៉េចក៏ធ្លាក់ប្រអប់ស្លាអស់អីចឹង" **ធនញ្ជ័យ** ជម្រាបថា "ខ្ញុំខ្លាចដើរមិនទាន់លោកតា បានជាខ្ញុំមិនហ៊ានឈប់រើស ត្បិតលោកតាផ្ដាំខ្ញុំថា ត្រូវតែរត់ឱ្យទាន់នោះអី"។ សេដ្ឋីបង្គាប់ទៀតថា "លើកក្រោយបើមានអីជ្រុះត្រូវរើសកុំឱ្យសល់"។ លុះព្រឹកឡើង សេដ្ឋីជិះសេះទៅគាល់ស្ដេចដូចធម្មតា។

ឯ **ធនញ្ជ័យ** យួរថង់ស្លាដើរតាមក្រោយដោយយកចិត្តទុកដាក់។ រំពេចនោះ សេះជុះអាចម៍នៅតាមផ្លូវ **ធនញ្ជ័យ** រើសអាចម៍សេះដាក់ថង់ស្លាមិនឱ្យសល់។ លុះទៅដល់ទីជំនុំ សេដ្ឋីទាញថង់ស្លាពី **ធនញ្ជ័យ** ស្រាប់តែឃើញអាចម៍សេះពេញថង់ក៏ខ្មាសអស់នាម៉ឺនពេញព្រះរាជរោង។

THUN CHEY walked home and told his parents, 'I want to serve as a servant at the official's residence.' His mother listened and told him, 'My dear son, I have not owed the official any money. So, how can I send you to be a servant like that?' 'I want to go to live there simply to outwit the official!' Chey told his mother. The mother allowed THUN CHEY to serve as a servant for the official from then on. Every morning the official asked THUN CHEY to hold a box of betel nut and follow him to the royal hall. THUN CHEY walked slowly, and THUN CHEY could not catch up with the official as the official was riding a horse. The official said, 'CHEY! Why can't you catch up with me?' 'Because I fear that I may drop the betel nut.' THUN CHEY replied. 'Next time, try to catch up with me and do not need to pick the betel nut up if it drops.' the official told THUN CHEY. THUN CHEY listened and followed the order of the official. On the next day, the official rode a horse and had THUN CHEY run after the horse. While running, betel nut was dropping out of the bag. Arriving at the royal hall, the official got off the horse and went to meet the royal mandarins of all levels. He then asked THUN CHEY to give him a box of betel nut for eating. THUN CHEY gave the box to the official and then he tried to find a suitable seat for his own. When the official saw the empty box, he was too embarrassed to speak out. After that, when they arrived back home, the official asked THUN CHEY to get in and asked, 'CHEY! Why did the betel nut drop from the bag?' 'I was afraid that I could not catch up with you. So, I did not stop to pick them up, and you had also told me not to care about picking up the nuts, but to catch up with you.' THUN Chey answered. Then, the official advised him, 'Next time, if something drops, you must pick them all up.' When the dawn broke, the official rode a horse to pay an audience to the King as usual, and THUN CHEY carried the bag of betel nut carefully. On the way, the horse defecated. THUN CHEY picked the horse dung and put them into the box of betel nut. When the official arrived at the meeting, he took the box of betel nut from THUN CHEY, and he saw the box filled with the horse dung. The official was so embarrassed in front of the royal mandarins at the meeting hall.

លុះទៅដល់ផ្ទះវិញ សេដ្ឋីប្រាប់ **ធនញ្ជ័យ** ថា "អាជ័យ! ឯងមិនបាច់ដើរតាមអញទៀតទេ ឯងទៅចាំចំការវិញចុះ"។ នៅពេល **ធនញ្ជ័យ** ចាំចំការ មានគោក្របីជាច្រើនចូលស៊ីដំណាំ **ធនញ្ជ័យ** មិនដេញសត្វទាំងអស់នោះទេ ធ្វើឱ្យដំណាំខ្ទេចខ្ទីគ្មានសល់។ សេដ្ឋីឃើញដូច្នេះក៏ស្ដីបន្ទោស **ធនញ្ជ័យ** ថា "អាជ័យ! ឯងរវល់ធ្វើអីបានជាបណ្ដោយ ឱ្យគោស៊ីដំណាំអស់យ៉ាងនេះ"។ **ធនញ្ជ័យ** ថា "បានជាខ្ញុំមិនដេញវា ត្បិតលោកតាគ្រាន់តែប្រើខ្ញុំឱ្យចាំចំការតែប៉ុណ្ណោះ"។



សេដ្ឋីថា "ឯងចាំចំការមិនបានទេ ឯងទៅឃ្វាលគោវិញ"។ **ធនញ្ជ័យ** ថា "ខ្ញុំឃ្វាលគោក៏បានដែរ តែគោញីទាំងអស់នោះជាប្រពន្ធរបស់ខ្ញុំ" រួចហើយ **ធនញ្ជ័យ** ក៏ចេញទៅឃ្វាលគោ។ នៅកន្លែងឃ្វាលគោ មានគោឈ្មោលមកពាក់គោញី **ធនញ្ជ័យ** បានចាប់គោឈ្មោលទាំងអស់នោះចងទុក។

ម្ចាស់គោឈ្មោលមកសុំយកទៅវិញ **ធនញ្ជ័យ** ប្រាប់ថា "គោអ្នកឯងបានលួចប្រពន្ធខ្ញុំ បើចង់បានគោទៅវិញទាល់តែយកប្រាក់មកលោះ។ កាលបើម្ចាស់គោបានឮ **ធនញ្ជ័យ** ថាដូច្នោះហើយ ក៏ទៅជម្រាបសេដ្ឋីអំពីរឿងនេះ។ សេដ្ឋីគិតថា "អញប្រើអាជ័យនេះនឹងកើតរឿងច្រើនទៀត" ក៏ហៅ **ធនញ្ជ័យ** មកសួរថា "មើល៍អាជ័យ! ដូចម្ដេចបានជាឯងទៅចាប់គោគេដូច្នេះ" **ធនញ្ជ័យ**ថា "ខ្ញុំបានជម្រាបលោកតាហើយថាមេគោទាំងនេះជាប្រពន្ធខ្ញុំ ឥឡូវគោឈ្មោលទាំងអស់នេះចង់ប្រពន្ធខ្ញុំ ហេតុដូច្នេះបានជាខ្ញុំចាប់ទុកប្ដឹងលោកតា"។ សេដ្ឋីស្ដាប់ **ធនញ្ជ័យ** និយាយដូច្នោះស្រដីថា "ឯងឱ្យគោទៅម្ចាស់គេវិញចុះ ហើយមិនបាច់ទៅឃ្វាលគោទៀតទេ អញឱ្យឯងធ្វើការក្នុងផ្ទះវិញ"។

Whey they were back home, the official told THUN CHEY, 'CHEY! You don't need to follow me to the royal hall any longer. But you must go to look after an orchard.' When THUN CHEY was at the orchard, there were a number of cattle eating the crops, but THUN CHEY did not chase the cattle out. The crops were completely destroyed. The official learned that and scolded THUN CHEY, 'CHEY! What were you doing while the cattle were eating the crops?' 'I did not drive them out because you had told me to only guard the field not the crops.' THUN CHEY argued. The official said, 'You are no longer allowed to guard the orchard any more, you must go to look after the cattle.' THUN CHEY replied, 'Yes, sir. But all the cows are considered as my wives.' Then, THUN CHEY walked out to look after the cattle in a field. At the field, oxen came to mate the cows. THUN CHEY captured all the oxen. Then, the owners of the oxen came to take them back, but THUN CHEY said, 'Your oxen intended to sleep with my wives. I will not give your oxen back unless you pay me a certain amount.' The owners of the oxen were all annoyed and went to complain to the official. The official thought, 'If I keep asking him to do things, he will spark more provocations.' Then, he called THUN CHEY to come in and asked, 'CHEY! Why did you capture their oxen?' 'I had informed you that the cows were all my wives. Their oxen wanted to mate my wives, so I captured them.' THUN CHEY replied. The official listened to THUN CHEY and said, 'You must give oxen back to the owners and don't need to guard the cattle any more. You must work indoors instead.'



មានថ្ងៃមួយ សេដ្ឋីកំពុងនិយាយនឹងនាម៉ឺនមួយក្រុម ប្រពន្ធសេដ្ឋីក៏ប្រើ **ធនញ្ជ័យ** ឱ្យទៅហៅប្ដីមកពិសាបាយ។ **ធនញ្ជ័យ** ស្ដាប់ហើយក៏ដើរទៅហៅសេដ្ឋីខ្លាំងៗថា "លោកតាៗមកពិសាបាយ" សេដ្ឋីខ្មាសគេណាស់ តែមិនស្រដីអ្វីឱ្យគេដឹងឡើយ។ សេដ្ឋីចុះពីលើសាលាទៅដល់ផ្ទះស្ដីបន្ទោសឱ្យ **ធនញ្ជ័យ** ថា "អាជ័យ! ដូចម្ដេចបានជាឯងស្រែកហៅអញខ្លាំងៗម្ល៉េះ? បើទៅឱ្យជិតចាំប្រាប់អញតិចៗទៅវាថី" **ធនញ្ជ័យ** ឮហើយក៏ចងចាំទុក។ មានថ្ងៃមួយ សេដ្ឋីនៅខាងក្រៅកំពុងបង្គាប់មនុស្សឱ្យធ្វើការ ភ្លើងក៏ឆេះផ្ទះសេដ្ឋី។ ប្រពន្ធភ័យខ្លាំងពេកក៏ប្រើ **ធនញ្ជ័យ** ឱ្យរត់ទៅហៅប្ដីជាប្រញាប់។ **ធនញ្ជ័យ** រហ័សរត់ទៅជិតសេដ្ឋីស្រែកតិចៗ។ សេដ្ឋីឃើញ **ធនញ្ជ័យ** ធ្វើមាត់ម្ហុបៗក៏មានមន្ទិលក្នុងចិត្តហើយក៏សួរថា "អាជ័យ! ឯងថាម៉េច អញស្ដាប់មិនឮទេ"។ **ធនញ្ជ័យ** ឱនខ្សឹបដាក់ត្រចៀកសេដ្ឋីថា "លោកតាភ្លើងឆេះផ្ទះហើយ"។ សេដ្ឋីស្ដាប់ច្បាស់ហើយក៏ប្រើ **ធនញ្ជ័យ** យករបស់ណាស្រាលៗដែលភ្លើងមិនទាន់ឆេះចេញ **ធនញ្ជ័យ** ម្ដីម្ដារត់ទៅយកសំបុកមាន់ប្រមាណជាង៣០សំបុកយកទៅទុកមួយអន្លើ។ លុះភ្លើងរលត់អស់ សេដ្ឋីប្រមូលរបស់ដែលយកបានពីក្នុងភ្លើងហើយក្រឡេកឃើញ **ធនញ្ជ័យ** ក៏សួរថា "អាជ័យ! ឯងយកបានរបស់អ្វីខ្លះ" **ធនញ្ជ័យ** បង្ហាញសំបុកមាន់ទាំងអស់។ សេដ្ឋីថា "យីអើ! របស់ច្រើនម៉ាគគោក ម៉េចក៏ឯងមិនយក ទៅយកអីសំបុកមាន់ទៅវិញ" **ធនញ្ជ័យ**ថា "ត្បិតលោកតាប្រើខ្ញុំឱ្យយកតែរបស់ស្រាលៗនោះអី"។

សេដ្ឋីថា "ឯងទៅហៅអ្នកណាដែលធ្វើឱ្យភ្លើងឆេះមកជួបអញ" **ធនញ្ជ័យ** ដើរទៅលើកជើងក្រានមកជូនសេដ្ឋីហើយជម្រាបថា "ជើងក្រាននេះហើយជាអ្នកដើមភ្លើង" សេដ្ឋីស្ដាប់ហើយពិចារណាថា "អញប្រើអាជ័យនេះមិនបានទេ បើប្រើវាតទៅទៀតឃើញថា នឹងបាត់បង់ទ្រព្យសម្បត្តិច្រើនជាងនេះទៅទៀត បើដូច្នេះ មានតែនាំវាទៅថ្វាយព្រះរាជាឱ្យស្រលះពីខ្លួនទើបល្អ"។

One day, the official was talking to a group of the royal mandarins, THUN CHEY, who was asked by the official's wife to invite her husband to have lunch, walked to the official and shouted at the top of his voice, 'Master, please go and have lunch.' The official was so embarrassed that he could not say any words. He was very angry, and walked down from the hall to his residence and blamed THUN CHEY, 'CHEY! Why did you shout at me so loudly? Why didn't you whisper in my ears softly?' THUN CHEY listened and tried to remember the advice. One day, when the official was supervising his men at work, his house caught fire. His wife was so horrified and ordered THUN CHEY to tell her husband urgently. THUN CHEY rushed to the official and whispered softly in his ear. The official was listening to THUN CHEY's whispering, but he couldn't hear him well and kept asking, 'CHEY! What are you saying? I cannot hear you at all.' 'Master, a fire is engulfing the house.' THUN CHEY whispered again. When the official heard that, he told THUN CHEY to take light things which hadn't been damaged by the fire yet. THUN CHEY rushed to bring out more than 30 nests of hence and chicken and kept them at a place. When the fire was put off, the official collected all things taken and saved from the fire and when he saw THUN CHEY, he asked, 'CHEY! What things did you get?' THUN CHEY showed him all the nests of hence and chicken. The official exclaimed, 'There were a lot of things that should had been taken, why did you take such nests of hence and chicken?' THUN CHEY replied, 'Because you had told me to take care of all the light things.' 'Go and get what caused the fire to me.' The official commanded. THUN CHEY went to fetch the cooking stove to show it to the official and said, 'This -cooking stove is the cause of the fire, sir.' Then, the official thought, 'I cannot keep THUN CHEY as my servant anymore. If he continues to live with me, a lot more properties will be lost and destroyed. Therefore, I should bring him to serve His Majesty the King.'



លុះព្រឹកឡើង សេដ្ឋីរៀបចំខ្លួនយក **ធនញ្ជ័យ** ទៅគាល់ស្តេច។ សេដ្ឋីក្រាបបង្គំទូលស្តេចថា "សូមទានប្រោស ទូលព្រះបង្គំជាខ្ញុំមានក្មេងម្នាក់មានប្រាជ្ញាណាស់ គេចេះកុហកដេញប្រាជ្ញាមិនទាន់ឡើយ ឥឡូវនេះទូលបង្គំយកគេមកថ្វាយជាខ្ញុំល្អងធូលីព្រះបាទ"។ មហាក្សត្រស្តាប់ហើយសួរ **ធនញ្ជ័យ** ថា "មើលអាជ័យ! ឯងចេះកុហកមែនទេ" **ធនញ្ជ័យ** ថា "ចេះមែនក្រាបទូល"។ ស្តេចថា "ឥឡូវឯងកុហកយើងមកមើល" **ធនញ្ជ័យ** ថា "ក្បួនកុហកនៅក្នុងផ្ទះឯណោះក្រាបទូល"។ ទើបស្តេចត្រាស់ប្រើមហាតលិកម្នាក់ទៅយកក្បួនកុហកអំពីផ្ទះ **ធនញ្ជ័យ**។ មហាតលិកទៅដល់ប្រាប់ម្តាយ **ធនញ្ជ័យ** ឱ្យយកក្បួនកុហកនោះចេញមក តែម្តាយ **ធនញ្ជ័យ** ថាគ្មានទេ។ មហាតលិកត្រឡប់មកវិញ ទូលព្រះអង្គតាមដំណើរ ទើបស្តេចមានព្រះបន្ទូលសួរ **ធនញ្ជ័យ** ថា "អាជ័យ! ឯងថាក្បួនកុហកនៅឯផ្ទះ ឥឡូវនេះម្តាយឯងថាគ្មានទេ" ទើប **ធនញ្ជ័យ** ថា "នេះហើយហៅថាកុហក សូមទ្រង់ជ្រាប"។ ស្តេចទាល់តំរិះក៏នៅស្ងៀម ហើយព្រមទទួល **ធនញ្ជ័យ** អោយរស់នៅក្នុងរាជវាំង។

When the dawn broke, the official brought THUN CHEY to the King. The official told the King, 'Your Majesty, I have a cunning boy who is very skillful in lying and cannot be outwitted. I now bring him over to be your servant.' The King listened and asked THUN CHEY, 'CHEY! You are good at telling lies, aren't you?' THUN CHEY responded, 'Yes, I am.' 'Now, lie to me!' The King commanded. THUN CHEY said, 'The doctrine of telling lies of mine is kept at home.' Then, the King ordered his servant to bring the doctrine of lies from THUN CHEY's house. The royal servant arrived and told CHEY's mother to give him doctrine. But his mother denied having it. The royal servant returned and told the King what happened. The King asked THUN CHEY, 'CHEY! You had told me that you had the doctrine of lies at home, but your mother denied having it.' THUN CHEY replied, 'This is a so-called telling a lie.' The King was baffled, staying calm and accepted THUN CHEY as his servant.



ស្តេចគិតថា "អញនឹងល្បងប្រាជ្ញាអាជ័យលមើល" ហើយស្តេចយាងទៅកំពង់ទឹក ហៅអស់នាម៉ឺនតូចធំលាក់ពងមាន់ម្នាក់មួយចុះទៅក្នុងទឹកជាមួយ **ធនញ្ជ័យ**។ លុះពួកគេងើបឡើងស្រែកថា "តុក្កតតពងមួយ..." ហើយយកពងមាន់មកថ្វាយស្តេចគ្រប់ៗគ្នា។ ឯ **ធនញ្ជ័យ** នៅក្រោយគេរកពងមាន់មិនបាន ងើបឡើងស្រែកថា "កឺគគិគលគក"។ ស្តេចមានព្រះបន្ទូលសួរថា "អាជ័យ! ឯណាពងមាន់" **ធនញ្ជ័យ** ទូលថា "ត្បិតទូលបង្គំនេះជាមាន់ឈ្មោលជាន់មាន់ញីទាំងអស់នេះទើបមានពង ក្រាបទូល" ស្តេចព្រះសណ្តាប់ហើយក៏កោតប្រាជ្ញា **ធនញ្ជ័យ** ណាស់ ហើយសួរ **ធនញ្ជ័យ** ថា "អាជ័យ! ឯងមានអាយុប៉ុន្មានឆ្នាំហើយ"។ **ធនញ្ជ័យ** ក្រាបទូលថា "ទូលបង្គំមានអាយុ១១ឆ្នាំហើយ។

The King then thought, 'I will try outwitting CHEY.' Then he went to a quay, calling the royal mandarins to stash an egg each and dipped into water with THUN CHEY. When they emerged, they made sound a hence usually makes and said, 'I hatched one egg' and they brought the eggs to the King. As for THUN CHEY, he was the last and couldn't hatch even an egg. So, he emerged and made sound a cock usually makes and said, 'I am a cock' The King asked, 'CHEY! Where is the egg?' THUN CHEY replied, 'Because I am a cock and I sleep with those hence, that's why they hatched those eggs.' The King listened to him and praised THUN CHEY's wit and asked THUN CHEY, 'CHEY! How old are you?' THUN CHEY replied, 'I am 11 years old.'

ថ្ងៃមួយស្តេចយាងទៅប្រពាតព្រៃហើយបង្គាប់ **ធនញ្ជ័យ** ថា "អាជ័យ! អញឱ្យឯងជិះដំរីដែលដាក់ក្រយាស្ងោយ បើជិះមិនទាន់អញទេឯងនឹងមានទោស។ ឯដំរីនោះទៀតសោតចាស់ដើរមិនទាន់គេឡើយ **ធនញ្ជ័យ** ធ្វើក្តោងហើយយកថ្នោលដោលផងព្រះមហាក្សត្រទៅដល់ព្រះពន្លារក **ធនញ្ជ័យ** មិនឃើញ ទ្រង់មានព្រះតំរិះយល់ឃើញថា អាជ័យនេះមុខជាខុសមិនខាន។ បន្តិចក្រោយមកទើប **ធនញ្ជ័យ** មកដល់ មហាក្សត្រសួរ **ធនញ្ជ័យ** ថា "ឯងជិះដំរីដូចម្តេចបានជាមិនទាន់អញអ៊ីចឹង" **ធនញ្ជ័យ** ទូលថា "ត្បិតដំរីមិនដើរ ទូលព្រះបង្គំជាខ្ញុំធ្វើក្តោងបើក ហើយយកថ្នោលដោលផង ទូលបង្គំមិនបានប្រហែសទេ សូមទ្រង់ជ្រាប" ស្តេចព្រះសណ្តាប់ហើយក៏នៅស្ងៀម។



ស្តេចគិតក្នុងព្រះទ័យថា "អាជ័យនេះមានប្រាជ្ញាណាស់ តើគិតធ្វើដូចម្តេចដើម្បីផ្ចាញ់ប្រាជ្ញាវាបាន" ស្តេចបញ្ជាអស់នាម៉ឺនសព្វមុខមន្ត្រីឱ្យរកសេះម្នាក់មួយហែព្រះអង្គទៅប្រពាធព្រៃ បើអ្នកណាគ្មានសេះជិះនឹងមានទោស។ មហាក្សត្របង្គាប់ **ធនញ្ជ័យ** ថា "អាជ័យ! ឯងហែអញទៅប្រពាធព្រៃហើយរកសេះជិះផង"។ **ធនញ្ជ័យ** រត់ទៅខ្ចីសេះគេ គ្មាននរណាម្នាក់ហ៊ានឱ្យសេះខ្ចីឡើយ។ **ធនញ្ជ័យ** ទាល់តំរិះក៏ទៅយកសេះកូនអុកក្តាប់នឹងដៃ ហែស្តេចទៅនឹងគេដែរ។ ព្រះមហាក្សត្រទៅដល់ព្រះពន្លាទតឃើញ **ធនញ្ជ័យ** រត់ខ្លាញ់ក៏សួរថា "អាជ័យ! អញឱ្យឯងជិះសេះមក ឥឡូវសេះឯងនៅឯណា?" **ធនញ្ជ័យ** បង្ហាញកូនសេះអុកទូលព្រះអង្គថា "សេះនេះហើយដែលទូលបង្គំជិះមក" ស្តេចទាល់តំរិះក៏នៅស្ងៀមមិនយកទោសអ្វីឡើយ។

One day, the King went out walking in the woods and commanded THUN CHEY, 'CHEY! You will ride an elephant with food supplies, and if you cannot catch up with me, you will be punished!' However, the elephant was too old to walk, so THUN CHEY invented a sail and used a gaff to pole. The King arrived at the royal tent and did not see THUN CHEY, so he thought that he would have an excuse to punish THUN CHEY. Moments later, THUN CHEY showed up, then the King asked, 'Why are you so late?' THUN CHEY said, 'Because the elephant was too old and walked too slow. I even made a sail and used a gaff to pole it as Your Majesty can see.' The King listened and did not say anything. The King thought, 'CHEY is very intelligent. What should I do to outwit him?' The King commanded the royal mandarins to find a horse each to escort him to the forest. If anyone does not have a horse, they will be punished. The King told THUN CHEY, 'CHEY! You must accompany me to the forest. But you have to search for a horse for yourself.' THUN CHEY tried to borrow a horse from other people. But no one dared to lend him a horse. THUN CHEY was so baffled that he decided to take a wooden horse used in chess game, holding it tightly to accompany the King. The King arrived at the royal tent, he asked THUN CHEY, 'CHEY! I command you to ride a horse, so where is the horse?' THUN CHEY showed the King the chess horse and told him, 'This is a horse I ride.' The King was baffled, staying calm and did not punish THUN CHEY.





នៅថ្ងៃបន្ទាប់ ស្ដេចបញ្ជាឱ្យ **ធនញ្ជ័យ** បោសសំអាតនៅក្រោមដំណាក់។ **ធនញ្ជ័យ** ក៏រៀបចំខ្លួនចូលទៅបោសសំអាតនៅទីនោះ អស់អ្នកម្នាងឃើញ **ធនញ្ជ័យ** នៅពីក្រោមក៏នាំគ្នាដើរទន្ទ្រាំជើងលើក្បាល **ធនញ្ជ័យៗ** គិតថា "អស់អ្នកម្នាងនេះចូលចិត្តដើរទន្ទ្រាំលើក្បាលអញណាស់ បើដូច្នេះអញធ្វើយ៉ាងណាកុំឱ្យស្ដេចប្រើអញមកបោសទីនេះទៀត"។ បន្ទាប់មក **ធនញ្ជ័យ** ក៏ស្រែកជេរខ្លាំងៗថា "មេចោរជកទង បានស៊ីក៏ដោយសារគូទ មិនបានស៊ីក៏ដោយសារគូទ" អ្នកម្នាងទាំងអស់ខឹងណាស់ក៏បបួលគ្នាទៅទូលពិតស្ដេច។ ស្ដេចក្រេវក្រោធជាខ្លាំងហើយបន្ទោស **ធនញ្ជ័យ** ថា "អាជ័យ! ហេតុអ្វីបានជាឯងជេរបញ្ចោរអស់ប្រពន្ធអញ"។ **ធនញ្ជ័យ** ថា "ទូលព្រះបង្គំជាខ្ញុំមិនបានជេរបញ្ចោរអស់អ្នកម្នាងនោះទេ កាលដែលទូលបង្គំចូលទៅបោសសំអាត មានសំបុកពីងពាងជាច្រើនជាប់ក្បាលទូលបង្គំទើបទូលបង្គំជេរពីងពាងយ៉ាងនេះ សូមទ្រង់ជ្រាប"។ តាំងពីថ្ងៃនោះមក មហាក្សត្រមិនដែលប្រើ **ធនញ្ជ័យ** ឱ្យទៅបោសក្រោមដំណាក់ទៀតឡើយ។

Next day, the King commanded THUN CHEY to clean the mess under the royal court. When THUN CHEY was preparing to clean, a group of ladies-in-waiting saw THUN CHEY and they started to trample above the head of THUN CHEY. 'These ladies-in-waiting like to walk over my heads, so I have to do something so that the King will not command me to clean here.' Then, THUN CHEY shouted with offensive language, 'Bitches! You live and eat upon your ass!' Those ladies-in-waiting were very furious and made a complaint to the King. The King was very aggravated, and berated THUN CHEY, 'CHEY! Why did you insult my wives?' THUN CHEY said, 'I did not reprimand those ladies-in-waiting. When I was cleaning mess, there were a lot of webs of spiders on my head; so, I insulted those spiders.' From then on, the King had never commanded THUN CHEY to clean under the court any more.





ព្រះអង្គមានព្រះតំរិះយល់ឃើញថា "អញដេញប្រាជ្ញាអាជ័យមិនទាន់ សោះបើដូច្នោះ អញនឹងលេងជល់មាន់ម្តង" ហើយហាមប្រាមមនុស្សទាំង អស់មិនឱ្យអាជ័យខ្ចីមាន់ឬលក់មាន់ឱ្យឡើយ។ លុះព្រឹកឡើង ស្តេចយកមាន់មកជល់នៅមុខព្រះលាន ហើយមានបន្ទូលនឹង **ធនញ្ជ័យ** ថា "អាជ័យ! ឯងទៅរកមាន់មកជល់នឹងមាន់អញឥឡូវនេះ"។ **ធនញ្ជ័យ** រកមាន់មិនបាន គិតថា "ព្រះមហាក្សត្រចង់ផ្ចាញ់ប្រាជ្ញាអញទៀតហើយ" ទើប **ធនញ្ជ័យ** ចាប់កូនមាន់មកជល់នឹងមាន់ស្តេច"។ លុះមកដល់ទ្រង់មានព្រះបន្ទូលថា "អាជ័យ! ឆាប់យកមាន់ឯងចេញមក" **ធនញ្ជ័យ** លឺបន្ទូលតឿនដូច្នោះ ក៏ចាប់កូនមាន់ដែលគ្រប់នឹងក្រណាត់សមកជល់នឹងមាន់ព្រះរាជា។ ឯកូនមាន់ឃើញមាន់ធំនោះស្មានថាជាមេរបស់វា ក៏រត់ទៅសសុលក្រោមពោះមាន់ជល់។ ចំណែកមាន់ព្រះរាជារសើបខ្លាំងពេកក៏រត់ចេញយ៉ាងលឿន។ **ធនញ្ជ័យ** ទះដៃស្រែកថា "ឈ្នះហើយៗ" ព្រះមហាក្សត្រទតឃើញដូច្នោះ ក៏អៀនព្រះទ័យពន់ពេកហើយប្រកាសមិនឱ្យ **ធនញ្ជ័យ** ចូលក្នុងរាជវាំងរយៈពេល១០ឆ្នាំ។ ឯ **ធនញ្ជ័យ** ស្តាប់ហើយក៏ទៅនៅឯផ្ទះរបស់ខ្លួនវិញ។

The King thought, 'I really cannot outwit CHEY; but I will play a cock fighting with him and I'll tell all the people not to lend and sell cocks to CHEY.' The next morning, the King started the cock fighting in front of the Royal Square and said to THUN CHEY, 'CHEY! Go and find cock to fight with mine.' THUN CHEY couldn't find even a cock and thought, 'The King wants to outwit me again. So, I will bring a baby chicken to fight with the King's cock.' When THUN CHEY arrived, the King asked, 'CHEY! Take out your cock.' At the King's command, THUN CHEY took out his chick to fight against the King's cock. But the chick was feeling nervous and thought that the big cock was its mother; so it ran to hide under the chest of the cock. The cock felt ticklish, so it ran away quickly from the ranch. THUN CHEY applauded, 'Well done! Win! Win.' The King saw that and felt so embarrassed that he ordered THUN CHEY to be banned from entering the Royal Palace for 10 years. Then, THUN CHEY returned to his home.



បួនថ្ងៃក្រោយមក ស្ដេចនិមន្តលោកគ្រូសង្ឃរាជចូលទៅទេសនាក្នុងព្រះរាជវាំង។ **ធនញ្ជ័យ** ដឹងដូច្នោះហើយ ក៏ទៅអង្គុយក្នុងសាលាជួបអស់នាម៉ឺនតូចធំនិយាយយ៉ាងព្រងើយថា "ថ្ងៃនេះស្ដេចនឹងហៅខ្ញុំចូលវាំងហើយ ឯនាម៉ឺនឮ **ធនញ្ជ័យ** ថាដូច្នោះក៏សើចទាំងអស់គ្នា។ បន្ទាប់មកលោកគ្រូសង្ឃរាជក៏និមន្តមកដល់ **ធនញ្ជ័យ** ស្រដីថា "មើលសក់ក្បាលខ្ញុំដូចសក់ក្ងោក មើលទៅមុខលោកគ្រាន់ជាងគូទខ្ញុំ"។ លោកគ្រូសង្ឃរាជស្ដាប់ហើយខ្ញាល់នឹង **ធនញ្ជ័យ** ណាស់ក៏ទៅទូលព្រះមហាក្សត្រអំពីរឿងនេះ។ ស្ដេចត្រាស់ប្រើមហាតលិកម្នាក់ឱ្យទៅហៅ **ធនញ្ជ័យ** ចូលគាល់។ **ធនញ្ជ័យ** មកដល់ក្រាបបង្គំដោយស្ងៀមស្ងាត់។ ឯព្រះមហាក្សត្រមានបន្ទូលសួរថា "អាជ័យ! ហេតុអ្វីបានជាឯងជៀលព្រះសង្ឃ?" **ធនញ្ជ័យ** ថា "ទូលព្រះបង្គំថាមែន តែមិនមែនជៀលត្មះលោកទេ ពាក្យនេះជាឧបមាឱ្យខ្លួនទូលព្រះបង្គំទេតើ ត្បិតព្រះអង្គបានចូលវាំង ឯទូលបង្គំមិនបានចូលវាំង ទើបស្រដីដូច្នេះ"។ ព្រះមហាក្សត្រស្ដាប់ហើយ ទើបមានព្រះបន្ទូលនឹងព្រះសង្ឃថា "សូមព្រះតេជគុណកុំខ្ញាល់នឹងអាជ័យអី វាឧបមាឱ្យខ្លួនវាទេតើ"។

Four days later, the King invited a monk chief to preach at the Royal Palace. THUN CHEY heard the news, so he came to sit in the hall to meet the royal mandarins, saying, 'The King will invite me to go the Royal Palace.' When all the royal mandarins heard that, they laughed at him. Immediately after the monk chief arrived, THUN CHEY said, 'My hair is as nice as peacocks,' but your face is only better than my ass.' The monk chief listened and got very angry with THUN CHEY, so he went to complain to the King about what had happened. The King ordered a royal servant to send THUN CHEY in. THUN CHEY arrived, paying tribute to the King quietly. And the King asked, 'CHEY! Why did you insult the senior monk chief? THUN CHEY replied, 'I really said so, but I didn't mean to insult him. I only told him because he was permitted to enter the Royal Palace, but I was not. That's why I said that. After listening, the King said to the monk chief, 'Please, be not be angry with CHEY, he only said to himself.'

ក្រោយមក ស្ដេចបញ្ជាអស់ស្រីៗក្នុងរាជវាំងទៅជុះអាចម៍ដាក់ផ្ទះ **ធនញ្ជ័យ**។ អស់ស្រីៗទៅដល់ប្រាប់ **ធនញ្ជ័យ** ថា "ត្បិតព្រះរាជាប្រើពួកយើងឱ្យមកជុះអាចម៍ដាក់ផ្ទះឯង" **ធនញ្ជ័យ** ថា "បើស្ដេចមានបន្ទូលដូច្នេះហើយ ខ្ញុំមិនហ៊ានឃាត់ពួកនាងទេ ចង់ជុះក៏ជុះចុះ តែកុំនោមឱ្យសោះ បើនោមផងទុកជាល្មើសនឹងព្រះបន្ទូលហើយ"។ **ធនញ្ជ័យ** ដើរមើលឃើញស្រីណានោមហើយ ក៏វាយស្រីនោះមិនញញើតដៃ។ ពួកស្រីៗខឹងណាស់ ក៏ទៅទូលស្ដេចតាមដំណើរ។ **នៅមានត**

Then, the King commanded all ladies-in-waiting in the Royal Palace to defecate at THUN CHEY's house. Those women arrived and informed THUN CHEY, 'The King told us to defecate at your house.' THUN CHEY responded, 'As it is his command, I don't dare to prevent all of you from doing so. You can defecate, but you must not urinate at the same time, otherwise all of you will violate the order.' THUN CHEY walked over and saw the women not only defecating but also urinating, so he hit them. The women were so furious that they went to complain to the King.



Reading Book

ពិភពរឿងនិទាន

The World of Stories



# បណ្ឌិតធនញ្ជ័យ
# Thun chey the sage

សៀវភៅជាឃ្លាំងនៃចំណេះដឹង

Books are the source of knowledge

M.37

ព្រះមហាក្សត្របញ្ជាទាហានឱ្យទៅចាប់ **ធនញ្ជ័យ** មកមានព្រះបន្ទូលសួរថា "នែអាជ័យ ! ដូចម្ដេចបានជាឯងដេញវាយអស់សាវឡឹកអញ?"។ **ធនញ្ជ័យ** ថា "ក្រាបទូលព្រះអង្គ បានជាទូលព្រះបង្គំវាយស្រីអស់ទាំងនោះ ព្រោះពួកនាងល្មើសនឹងព្រះបន្ទូល" "ល្មើសនឹងស្អីខ្លះទៅ" (ស្ដេចសួរបញ្ជាក់)។ **ធនញ្ជ័យ** ថា "ត្បិតព្រះអង្គបង្គាប់ឱ្យនាងទៅជុះអាចម៍ដាក់ផ្ទះទូលបង្គំ តែពួកនាងមិនត្រឹមតែជុះប៉ុណ្ណោះទេ ថែមទាំងនោមទៀតផង ។ ហេតុដូច្នេះហើយទើបទូលបង្គំវាយយ៉ាងនេះ សូមទ្រង់ជ្រាប" ។ ព្រះមហាក្សត្រទ្រង់សណ្ដាប់ហើយក៏នៅស្ងៀមមិនបានដាក់ទោសអ្វីដល់ **ធនញ្ជ័យ** ឡើយ ។ ក្រោយមកភាពល្បីល្បាញរបស់ **ធនញ្ជ័យ** ក៏ឮទៅដល់ស្រុកចិន ។ ស្ដេចស្រុកចិនជំនុំអស់នាហ្មឺនថា នឹងទៅធ្វើចំណោទនៅស្រុកខ្មែរដើម្បីផ្ចាញ់ប្រាជ្ញា **ធនញ្ជ័យ** ។ ស្ដេចក្រុងចិនក៏ថ្លែងព្រះរាជសារមកថ្វាយស្ដេចស្រុកខ្មែរ ក្នុងសារនោះបញ្ជាក់ថា ស្ដេចស្រុកចិននាំផ្លែឪឡឹកបី និងសំពៅ៥០០ ក្នុងសំពៅនីមួយៗមានមនុស្សចំនួន៥០០នាក់នាំមកធ្វើចំណោទនឹងអ្នកប្រាជ្ញស្រុកខ្មែរ បើអ្នកប្រាជ្ញស្រុកខ្មែរឆ្លើយត្រូវ យើងប្រគល់សំពៅ៥០០ និងមនុស្សទាំងអស់ ។ បើឆ្លើយមិនត្រូវទេ យើងនឹងយកស្រុកខ្មែរជាចំណុះ" ។

The King ordered the soldiers to arrest and bring THUN CHEY to him and then he asked, 'Hey! Chey! Why did you hit my servants?' THUN CHEY answered, 'Your Majesty, because they disobeyed your order.' 'What did they do?' the King confirmed. 'Your Majesty, you ordered them to defecate at my house; however, they not only defecated, but also urinated; so, I hit them,' answered CHEY. Hearing that, the King kept quiet and didn't punish THUN CHEY. Later, the fame of THUN CHEY was known and widespread up to China. The King of China consulted his mandarins and that they would go to challenge THUN CHEY in Khmer Empire. Then, the King of China sent a letter to the King of Khmer Empire. The letter stated that the King of China would send three watermelons and 500 junks with 500 crew members on each junk. They would have riddle for Khmer scholars to answer. If Khmer scholars could find the right answers to the riddle, the King of China would provide the 500 junks together with all crew members on board to the Khmer Empire. In contrast, the Khmer Empire would be taken as a colony of China if the Khmer sage could not find the answers to the riddle.



ព្រះរាជាជ្រាបហើយក៏ប្រាប់ **ធនញ្ជ័យ** តាមដំណើររឿង ។ **ធនញ្ជ័យ** ទូលព្រះអង្គថា "សូមព្រះអង្គកុំព្រួយព្រះទ័យអី ធានាលើទូលបង្គំចុះ" ប៉ុន្តែក្នុងចិត្ត **ធនញ្ជ័យ** ភ័យណាស់ដែលអួតថាខ្លួនឯងជាអ្នកប្រាជ្ញ ។ **ធនញ្ជ័យ** រិះរកគ្រប់មធ្យោបាយដែលត្រូវធ្វើ។ ប៉ុន្តែ **ធនញ្ជ័យ** គិតអ្វីមិនយល់ទាល់តែសោះ ក៏និយាយតែម្នាក់ឯងថា "ស្អែកនេះព្រះរាជាឱ្យអញដោះប្រស្នានឹងអ្នកប្រាជ្ញចិន បើឆ្លើយមិនត្រូវទេ ទ្រង់នឹងសម្លាប់អញចោលមិនខាន ។ បើដូច្នេះអញគង់តែស្លាប់ដដែល អញមុជទឹកឱ្យស្លាប់ទៅប្រសើរជាង"។ ដល់វេលាយប់ **ធនញ្ជ័យ** មុជទឹកយ៉ាងជ្រៅហើយអណ្តែតខ្លួនឡើងរសាត់ឆ្ងាយទៅៗរហូតដល់សំពៅចិន ។ **ធនញ្ជ័យ** ស្តាប់ឮពួកចិននិយាយគ្នាថា "បើយើងធ្វើប្រស្នាផ្លែឪឡឹកនេះហើយ តើយើងមានប្រស្នាអ្វីទៀត ត្បិតផ្លែឪឡឹកមានតែបី ផ្លែ១មានគ្រាប់១ ផ្លែ១ទៀតមានគ្រាប់២ ឯផ្លែមួយទៀតមានគ្រាប់តែបីប៉ុណ្ណោះ"។ អ្នកប្រាជ្ញម្នាក់និយាយថា "ពេលយើងធ្វើប្រស្នានេះចប់ យើងនឹងដាក់ប្រស្នាមួយទៀត គឺយកសាច់ជ្រូកមួយនាលិឱ្យស្តេចខ្មែរសោយឱ្យបានពីរឆ្នាំ មិនឱ្យប្រឡាក់អំបិល មិនឱ្យធ្វើងៀតឯសាច់ក៏មិនឱ្យខូច"។ នាម៉ឺនម្នាក់សួរថា "ធ្វើដូចម្តេចនឹងបានពីរឆ្នាំទៅ"។ អ្នកប្រាជ្ញចិនបញ្ជាក់ទៀតថា "គឺនៅថ្ងៃចុងឆ្នាំ និងថ្ងៃដើមឆ្នាំ យើងយកសាច់ជ្រូកមកធ្វើម្ហូបតែពីរបីថ្ងៃក៏រាប់ថាពីរឆ្នាំដែរ ត្បិតឆ្នាំចាស់១ថ្ងៃ ដើមឆ្នាំថ្មី១ថ្ងៃ "។ ពួកនាហ្មឺនឮដូច្នេះក៏ត្រេកអរណាស់ ថាស្រុកខ្មែរប្រាកដជាធ្លាក់ក្នុងកណ្តាប់ដៃរបស់ខ្លួនមិនខានឡើយ។ **ធនញ្ជ័យ** ឮសព្វគ្រប់អស់ហើយក៏ត្រឡប់ទៅផ្ទះវិញដោយចិត្តត្រេកអរ។

Having read the letter, the King of the Khmer Empire told THUN CHEY what it was all about. Then THUN CHEY replied, 'Your Majesty, don't worry about that. Leave it all to me.' But THUN CHEY was very worried, being the sage of the country. THUN CHEY was thinking of ways to work this out, but he could not get any idea. He murmured to himself, 'The King assigned me as the Khmer scholar to meet the Chinese scholars to solve the riddle. If I cannot solve the riddle, the King will take my life. There is no doubt that I would not be able to answer the riddle, and it is obvious that the King would kill me afterwards. So, it is better to drown myself to death.' When the night time came, THUN CHEY dived deeply and floated his body up on the water surface and drifted on and on until he reached the Chinese junks.



At that time, THUN CHEY overheard the Chinese scholars on the junk talking to one another, 'What should we do next after we have done the watermelon riddle? We have only three watermelons altogether, and here is only one seed in the first watermelon, two seeds in another watermelon, and three seeds in the third one.' One Chinese man said, 'We will have one more riddle to ask after they have solved the watermelon riddle; that is one Niel (about 600 kg) of pork for the King of Khmer Empire to eat for 2 years without making the meat to be salty or dried and the meat must not be spoiled.' 'How can it be done?' One of the Chinese scholars wondered. One of the other Chinese scholars answered, 'That can be done on the last day of the previous year and the first day of the new year. We use that pork to cook within that period. Even if it is only two or three days, they are still considered as the period of two years because one day is in the previous year and another day is in the new coming year.' All Chinese mandarins were very excited after knowing this secret and they strongly believed that Khmer Empire shall belong to them. After hearing the secret answers, THUN CHEY returned home happily.

លុះដល់វេលាកំណត់  ពួកចិនយកផ្លែឪឡឹកទាំងបីដាក់ក្នុងព្រះរាជរោង ។ គ្រប់ប្រស្នាដែលអ្នកប្រាជ្ញចិនសួរ **ធនញ្ជ័យៗ** ឆ្លើយបានយ៉ាងក្បោះក្បាយមិនទាក់ទើរត្រង់ណាបន្តិចឡើយ ។ ព្រះរាជាទ្រង់យកសំពៅទាំង៥០០ ទុកតែសំពៅមួយឱ្យនាម៉ឺននិងអ្នកប្រាជ្ញចិនជិះត្រឡប់ទៅស្រុកវិញតែប៉ុណ្ណោះ។  ចាប់ពីថ្ងៃនោះមក  អ្នកប្រាជ្ញស្រុកចិនខ្លាចប្រាជ្ញា **ធនញ្ជ័យ** មិនហ៊ានមកចោទប្រស្នាទៀតឡើយ  ប៉ុន្តែនឹកខ្វាសក្នុងចិត្តថា  បើអត់អំពី **ធនញ្ជ័យ** ទៅកាលណា  នឹងទៅចោទជាប្រស្នានៅស្រុកខ្មែរម្តងទៀត ។ ក្រោយមក ស្តេចស្រុកខ្មែរ  ទ្រង់ព្រះចិន្តាគិតដល់ប្រាជ្ញា **ធនញ្ជ័យ** ហើយខ្លាច **ធនញ្ជ័យ** ដណ្តើមយករាជបល្ល័ង្ក  ស្តេចបញ្ជាឱ្យ **ធនញ្ជ័យ** ទៅនៅស្រុកឆ្ងាយក្បែរទន្លេ ។  **ធនញ្ជ័យ** ប្រាប់អស់ប្រជារាស្ត្រដែលរស់នៅទីនោះថា  "ត្បិតហ្លួងមានព្រះបន្ទូលឱ្យខ្ញុំមកធ្វើជាអ្នកធំនៅក្នុងស្រុកនេះ  ឥឡូវខ្ញុំប្រាប់អ្នករាល់គ្នាថា  បើធ្វើដំណើរតាមជើងទឹកត្រូវប្រាប់ខ្ញុំជាមុន ខ្ញុំនឹងកត់ថ្លៃទន្លេ  និងព្រែក  បើអ្នកណាមិនប្រាប់ខ្ញុំទេ  នោះបានសេចក្តីថាខុស  ខ្ញុំនឹងទារពន្ធមិនប្រណីឡើយ" ។  **ធនញ្ជ័យ** ចាប់ផ្តើមធ្វើស្រែនៅកន្លែងទឹករាក់  ឯកន្លែងទឹកជ្រៅ **ធនញ្ជ័យ** បាចអង្កាមពេញទន្លេហាមប្រាមមិនឱ្យអ្នកណាអុំទូកឆ្លងកាត់ឡើយ  បើមិនដូច្នោះទេ **ធនញ្ជ័យ**  ចាប់ឱ្យសងជាប្រាក់៣០តម្លឹងចំពោះមនុស្សម្នាក់  និងទូកមួយ ។ អស់រាស្ត្ររកស៊ីក្នុងទន្លេជៀសសំណាបនិងអង្កាម  **ធនញ្ជ័យ** មិនបានក៏នាំគ្នាទៅទូលស្តេចតាមដំណើររឿង ។

The riddle day came. The Chinese scholars brought three watermelons into the royal hall. THUN CHEY could answer all the riddles posed by the Chinese scholars. The Khmer King got all the 500 junks, but returned one junk to Chinese scholars to travel back to their Kingdom. From that day, the Chinese scholars did not dare to challenge THUN CHEY anymore. However; they still kept in mind that with the absence of THUN CHEY, they would come back to challenge the King of Khmer Empire again. Later, the Khmer King thought that THUN CHEY was very intelligent, and he was afraid that THUN CHEY would seize the throne from him; thus, he decided to exile THUN CHEY to live in a far and remote district nearby the river.

In the district THUN CHEY announced, 'The King had appointed me to be a highest ranking official here. And now I would like to inform all of you that whenever you need to make a trip through the waterways, all of you shall inform me first so that I can charge your trip through the river and creeks. If anyone has not informed me, it means that they have made a mistake, and I shall levy the tax from them heavily.' THUN CHEY began to grow rice in the shallow water, and he scattered husks all over in the deep water, and he banned all the people from going pass, otherwise he would fine 30 Damleung for a person. All people using the river could not make the detours from the scattered husks. So, they went to inform the King about what had happened.



ព្រះមហាក្សត្រឆ្ងល់ព្រះទ័យនឹង **ធនញ្ជ័យ** ណាស់ ហើយហៅ **ធនញ្ជ័យ** មកមានព្រះបន្ទូលសួរថា "អាជ័យ ! អញឱ្យឯងទៅរស់នៅតាមទន្លេធ្វើស្រែយកស្រូវ ចុះហេតុអីក៏ឯងធ្វើដូច្នេះ ឯងលក់រាស្ត្រនោះធ្ងន់ធ្ងរណាស់ បើឯងចង់យក ឯងយកតែមួយបាទបានហើយ" ។ ឯ **ធនញ្ជ័យ** ទទួលព្រះបន្ទូលហើយ ក៏ទៅយកបាត្រអំពីលោកសង្ឃ ហើយទៅប្រាប់អស់មនុស្សដែលចាប់លក់នោះថា "ត្បិតហ្លួងមិនឱ្យយកប្រាក់៣០តម្លឹងទេ ទ្រង់ឱ្យខ្ញុំយកតែមួយបាត្រអំពីអស់លោកវិញ" ។ ប្រាប់ហើយ **ធនញ្ជ័យ** យកបាត្រមកវាល់ប្រាក់អំពីរាស្ត្រ ។ អស់រាស្ត្រយកប្រាក់មកវាល់មិនពេញបាត្រ ក៏នាំគ្នារត់ទៅទូលស្តេចម្តងទៀត ។



ហើយស្ដេចមានព្រះបន្ទូលសួរ **ធនញ្ជ័យ** ថា "អាជ័យ ! អញឱ្យឯងយកបាត្រទៅវាល់ប្រាក់ពីរាស្ដ្រកាលណា?" ឯ **ធនញ្ជ័យ** ទូលតបថា "ព្រះអង្គបង្គាប់ទូលបង្គំឱ្យយកប្រាក់មួយបាត្រវិញ" ។ ឯព្រះមហាក្សត្របញ្ជាក់ថា "អញឱ្យឯងយកប្រាក់៤ស្លឹង តែគេហៅមួយបាទ" ។ ស្ដេចមានព្រះបន្ទូលទាំងក្រេវក្រោធថា "អាជ័យ ! ឯងនេះធ្វើឱ្យក្ដៅទឹកដីអញណាស់ ទុកឯងទៀតមិនបានទេ" ។ ទើបស្ដេចបញ្ជាពេជ្ឈឃាតឱ្យយក **ធនញ្ជ័យ** ទៅសម្លាប់ក្នុងទឹកទន្លេទុកជាបម្រាម ។

The King was very doubtful about THUN CHEY's acts, so he asked THUN CHEY to meet him. 'Hey! Chey, I told you to live and grow rice near the river, but why have you been doing so? You have fined those people too much. If you want to fine them, it should be just only one Bart (unit of money at that time, which was equal to 4 Sleungs in which 1 Sleung was equal to 20 cents, and it also has another meaning as a begging rice bowl of a Buddhist monk). Following the King's order, (THUN CHEY regarded the word 1 Bart as a rice bowl of a Buddhist monk in stead), THUN CHEY took a rice bowl from a monk and went to inform the people in the area, 'The King did not allow me to take 30 Damleungs from all of you, but he ordered me to collect the fine which is equal to one full begging rice bowl.' After that he took a rice bowl of monk to fill with money collected from the people. No one could fully fill the money in that begging rice bowl; therefore, they went to inform the King again. The King asked THUN CHEY, 'Chey! Did I tell you to use a Bart (a rice bowl of monk) to collect the money from the people?' THUN CHEY replied, 'You told me not to take 30 Damleungs but to take one Bart (a rice bowl) full of money from them.' The King clarified, 'I commanded you to take 4 Sleungs, which is also equal to 1 Bart.' The King spoke to THUN CHEY furiously, 'Chey! You have made a lot of troubles to the Kingdom, thus I can no longer let you live here.' Hence, the King ordered a capital punishment to THUN CHEY by asking the executioners to execute him in the water.



ពេជ្ឈឃាតក៏ចាប់ **ធនញ្ជ័យ** ចងនៅកណ្ដាលទូក ។ នៅលើទូក **ធនញ្ជ័យ** គិតក្នុងចិត្តថា "អញនឹងបញ្ឆោតពេជ្ឈឃាតកុំឱ្យសម្លាប់អញបាន"។ រួចហើយក៏ងាកមកប្រាប់ពេជ្ឈឃាតថា "បងប្អូនទាំងអស់គ្នាឥឡូវនេះខ្ញុំជិតស្លាប់ហើយ ខ្ញុំសុំលេងជាមួយបងប្អូនឱ្យសប្បាយម្ដង" ។ ពេជ្ឈឃាតស្ដាប់ពាក្យ **ធនញ្ជ័យ** ហើយគិតថា ទោះជា **ធនញ្ជ័យ** ចង់រត់ក៏រត់មិនរួចដែរ" ទើបពួកគេស្រាយចំណងដៃ **ធនញ្ជ័យ** ចេញ ។ ឯ **ធនញ្ជ័យ** បង្គាប់ថា "បើខ្ញុំថាអាជ័យធ្លាក់ទឹក អ្នកទាំងអស់គ្នាថា ហៃអើៗ" ។ អ្នកអុំទូកក៏ព្រមថាតាម **ធនញ្ជ័យ** មែន ។ លុះមើលទៅឃើញថាសមល្មមហើយ **ធនញ្ជ័យ** ក៏លោតទឹកប្រូង ។ ឯអ្នកកន្សៃទូកស្រែកថា "អាជ័យធ្លាក់ទឹក" អ្នកក្បាលទូកស្រែកថា "ហៃអើៗ" ។ **ធនញ្ជ័យ** ប្រឹងមុជទឹកទៅដល់ត្រើយម្ខាង ហើយចូលទៅជួបលោកគ្រូសង្ក្រាជក្នុងកុដិយកស្បង់ចីវរស្លៀក ហើយបួសជាព្រះសង្ឃយ៉ាងស្ងៀមស្ងាត់ ។ អស់អ្នកអុំទូកដឹងថា **ធនញ្ជ័យ** លោតទឹកទៅហើយក៏បន្ទោសគ្នាទៅវិញទៅមក ហើយវិលទៅទូលស្ដេចថា "សូមទានជ្រាប ត្បិត **ធនញ្ជ័យ** ខឹងចិត្តលោតទឹកទាំងចំណងលិចបាត់មិនឃើញអណ្ដែតមកវិញឡើយ" ។ ព្រះមហាក្សត្រសណ្ដាប់ហើយក៏ហីទៅ ។ លុះដល់យូរបន្តិចទៅក៏ឮដំណឹងទៅដល់ស្រុកចិនថា អ្នកប្រាជ្ញស្រុកខ្មែរឥឡូវនេះស្លាប់បាត់ទៅហើយ ។ ស្ដេចស្រុកចិនបញ្ជាឱ្យអាចារ្យ៤នាក់ទៅចោទជាប្រស្នានៅស្រុកខ្មែរហើយផ្ញើរាជសារមកថ្វាយស្ដេចខ្មែរ។

ក្នុងសារនោះមានសេចក្ដីថា "ព្រះរាជសារមេត្រីអំពីស្ដេចក្រុងចិន ថ្វាយមកស្ដេចស្រុកខ្មែរសូមជ្រាប ត្បិតឮដំណឹងថា ស្រុកខ្មែរមានឈ្មោះ **ធនញ្ជ័យ** ជាអ្នកប្រាជ្ញធំ ឥឡូវនេះយើងប្រើអ្នកប្រាជ្ញស្រុកយើងឱ្យមកចោទជាប្រស្នាភ្នាល់គ្នា បើអ្នកប្រាជ្ញនគរណាចាញ់នឹងយកនគរនោះជាចំណុះ" ។ ព្រះរាជាជ្រាបហើយក៏ស្ដាយ **ធនញ្ជ័យ** ពន់ពេក ។

The executioners tied THUN CHEY in the middle of the boat. Being tied up on the boat, THUN CHEY thought that, 'I have to play a trick with those executioners so that they would not kill me.' After that he turned to talk to the executioners, 'Hey friends, I am going to die soon, but I want to happily play with you before I die.' After hearing that, executioners thought that THUN CHEY might want to escape; however, it was impossible to do so. Therefore, they untied him, and THUN CHEY told the executioners how to play the game, 'When I say, 'Chey is jumping into the water,' you all say 'Cheer! Cheer! The boat rowers agreed with him. When having an opportunity, THUN CHEY jumped into the water. One of the boat rowers saw THUN CHEY jumping into the water and shouted, 'THUN CHEY is jumping into the water!' The others thought it was the game and shouted, 'Cheer! Cheer!' THUN CHEY swam hard until he could get to the river bank and came to meet a Buddhist monk chief in a monastery and THUN CHEY was ordained as a monk. After realizing that THUN CHEY had escaped, the boat rowers blamed one another. Then they went to inform the King that THUN CHEY jumped in tie into the water and they didn't see him float up again. After hearing that, the King did not care anymore. The time passed by. The news of THUN CHEY's death finally reached the Chinese scholars. The King of China sent 4 scholars to the Khmer Empire again and a letter to the Khmer King. The letter stated, 'This is a friendly letter of King of China to the King of the Khmer Empire. It was known that the Khmer Empire has a great sage named THUN CHEY. So, I would like to send my scholars to contest with him. If my scholars from one of the two Kingdoms lose, the lost Kingdom shall be considered as the colony of the one that wins.' The King was very regretful for what he had done to THUN CHEY, after he had learned about the news.

និយាយពីលោកសង្ឃជ័យវិញគិតថា "អាត្មាអញនឹងទៅបិណ្ឌបាតនៅរាជវាំងម្តង តើព្រះអង្គនៅស្គាល់អាត្មាអញដែរឬទេ?" ។ លោកជ័យគិតដូច្នោះហើយក៏ឃ្លុំចីវរ ស្ពាយបាត្រនិមន្តទៅរាជវាំងជាមួយនឹងលោកសង្ឃឯទៀត ។ លុះព្រះរាជាដាក់បាត្រ ព្រះសង្ឃមុនផុតហើយ លោកជ័យនៅក្រោយគេក៏និមន្តមកដល់ មហាក្សត្រទតឃើញ **ធនញ្ជ័យ** ក៏មានបន្ទូលថា "មើលទៅមុខលោកដូចជាមុខអាជ័យ" ។ ឯលោកជ័យទូល ថា "ជ័យហើយថាមិនជ័យ" ហើយក៏និមន្តហួសទៅ ។ ស្តេចមានព្រះតម្រិះយល់ឃើញ ថា **ធនញ្ជ័យ** មិនទាន់ស្លាប់ទេក៏បញ្ជាអាមាត្យទៅរក **ធនញ្ជ័យ** នៅឯវត្ត ។ អាមាត្យស្វែង រក**ធនញ្ជ័យ** ជាច្រើនវត្តរហូតទៅដល់វត្តមួយក៏ឃើញ **ធនញ្ជ័យ** បួសជាព្រះសង្ឃ ក៏ចូល និមន្តលោកជ័យទៅជួបស្តេចៗទតឃើញ **ធនញ្ជ័យ** ក៏ត្រេកអរហើយមានព្រះបន្ទូលសួរ ថា "តើលោកជ័យអន់ចិត្តនឹងខ្ញុំព្រះករុណាដែរឬទេ?" ។ លោកជ័យថ្វាយព្រះពរថា ទេ ទើបទ្រង់បន្តទៀតថា "ត្បិតមានអាចារ្យមកពីស្រុកចិនគេមកចោទប្រស្នាយកនគរយើង នេះ តើព្រះតេជគុណគិតយ៉ាងណាដែរ?" ។ លោកជ័យថ្វាយព្រះពរថា "អាត្មាដោះ ថ្វាយជូនបាន សូមព្រះអង្គទុកព្រះទ័យចុះ អាត្មាភាពនឹងសឹកនៅថ្ងៃនេះ" ។ លោកជ័យ និមន្តទៅវត្តហើយស្លៀកសំពត់អាវក្រវាត់ក្រមា ហើយត្រឡប់មកគាល់ស្តេចៗទតឃើញ មានព្រះបន្ទូលថា "បណ្ឌិតជ័យមើលទៅស្អាតណាស់ សមជាបណ្ឌិតអ្នកប្រាជ្ញស្រុក ខ្មែរមែន បើដូច្នេះឯងឱ្យអាចារ្យចិនឡើងមកនៅថ្ងៃណា?" ។ បណ្ឌិតជ័យក្រាបទូលថា "៣ថ្ងៃទៀត" ។

The Venerable monk THUN CHEY thought, 'I will go to beg at the Royal Palace and see if the King still recognizes me.' Then THUN CHEY wore the yellow robes with his hand carrying a rice bowl and walked towards the Royal Palace accompanied by other monks. After offering all the food to the monks, then the King looked at the last monk in the row and saw THUN CHEY. So, he said, 'You look very similar to THUN CHEY.' The Venerable monk THUN CHEY said, 'Truly, that is me,' and left the King. The King realized that THUN CHEY had not yet died; thus he commanded his soldiers to get THUN CHEY back from the monastery. After looking for THUN CHEY at many monasterys, the soldiers saw the venerable monk THUN CHEY in a monastery, and they invited him to see the King. The King was very excited and said,

The venerable monk Chey, please do not feel upset with me?' The Venerable monk THUN CHEY replied, 'No, I don't.' Then the King continued to tell the Venerable monk Chey, 'The scholars from China are coming to compete with us through a riddle contest in the purpose of colonizing our Kingdom. 'What do you think?' Venerable monk replied, 'I will solve that riddle for you, Your Majesty. Trust me. I will leave the monk-hood today.' The Venerable monk Chey went to monastery and changed the yellow robes into a causal shirt and sampot with a scarf tied around his waist and came back to meet the King. The King said, 'Sage Chey, you look so handsome and you deserve to be called the sage of the Khmer Empire. When will you let the Chinese scholars have a riddle with us?' Sage Chey replied, 'In three days' time.'



លុះដល់ថ្ងៃសន្មត អាចារ្យចិនក៏ឡើងមកចោទប្រស្នា ប៉ុន្តែពួកគេភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលដែលឃើញ **ធនញ្ជ័យ** នៅចំពោះមុខ ។

-អាចារ្យចិនជួប **ធនញ្ជ័យ** ក៏ធ្វើប្រស្នាចង្អុលទៅលើហើយចង្អុលចុះមកដី ។

-**ធនញ្ជ័យ** ចង្អុលទៅព្រះអាទិត្យ ហើយចង្អុលមកខ្លួនឯង ។

-អាចារ្យចិនសួរ **ធនញ្ជ័យ** ថា "កាលដែលយើងចង្អុលទៅលើហើយចង្អុលមកដី តើឯងយល់ឃើញដូចម្ដេច?"

-**ធនញ្ជ័យ** ឆ្លើយថា "អ្នកឯងចង្អុលទៅលើ គឺចង់សួរខ្ញុំថា មានអ្វី?

ខ្ញុំចង្អុលទៅព្រះអាទិត្យចង់ប្រាប់ថា នៅលើមេឃមានព្រះអាទិត្យ និងព្រះចន្ទ។ ហើយអ្នកចង្អុលមកដីនោះ ព្រោះអ្នកចង់សួរខ្ញុំថា មានអ្វី? ។ ខ្ញុំចង្អុលមកខ្លួនខ្ញុំមានន័យថា នៅលើដីមានមនុស្ស?" ។ បន្ទាប់ពីពួកគេឆ្លើយប្រស្នាគ្នារួចហើយ អាចារ្យចិនលា **ធនញ្ជ័យ** វិលទៅសំពៅវិញ ។

The Chinese scholars came on the arranged date. But they were terribly surprised to see THUN CHEY alive and standing right in front of them.



- The contest started. A Chinese scholar pointed his finger up to the sky and then down to the earth.

-THUN CHEY pointed to the sun, and then pointed to himself. -The Chinese scholar asked THUN CHEY, 'What dose it means when I pointed up to the sky and then down to the earth?'

-THUN CHEY answered, 'When you pointed up to the sky, it means what is on the sky? When I pointed to the sun, it means that there are the sun and the moon in the sky. When you pointed to the earth, it means what are there on earth? I pointed to myself. It meant that there are people on earth.' After the first round of contest was over, the Chinese scholar said good bye to THUN CHEY and went back to their junk.



លុះព្រឹកឡើង អាចារ្យចិនមកជួប **ធនញ្ជ័យ** ម្តងទៀត ។ អាចារ្យចិនធ្វើដៃជារង្វង់ ឯ **ធនញ្ជ័យ** ធ្វើបត់ដុំដៃបង្ហាញ ។ អាចារ្យចិនលាម្រាមដៃទាំង៥បង្ហាញមក **ធនញ្ជ័យ**ៗ បង្ហាញម្រាមមួយ ។ អាចារ្យចិនក៏លា **ធនញ្ជ័យ** ទៅសំពៅវិញ ឯ **ធនញ្ជ័យ** ក៏ទៅផ្ទះវិញដែរ ។ លោកគ្រូសង្ក្រាជឃើញ **ធនញ្ជ័យ** ដោះប្រស្នានឹងអាចារ្យចិនក៏និមន្តទៅជួប **ធនញ្ជ័យ** សួរអំពីប្រស្នាទាំងនេះ ។ **ធនញ្ជ័យ** ទូលថា "ចិនធ្វើដៃរង្វង់ ខ្ញុំថាជាអង្រុតរុតត្រី ទើបខ្ញុំបង្ហាញកែងដៃចង់បញ្ជាក់ថា បើអង្រុតត្រីដូច្នោះ តើរុតបានត្រីប៉ុន្មាន? ចិនបង្ហាញម្រាមដៃប្រាំ ថាបានត្រីមួយធ្វើងៀតបាន៥ចម្រៀក ខ្ញុំបង្ហាញចង្អុលដៃ១ ថាស៊ីមួយថ្ងៃមួយចម្រៀក ។ លោកគ្រូសង្ក្រាជសណ្តាប់ហើយក៏វិលទៅកុដិវិញ ។ សម្តេចចៅហ្វាយក៏ចង់ដឹងអំពីប្រស្នាចិននោះដែរ ។ **ធនញ្ជ័យ** ប្រាប់ថា "ចិនឱបដៃជារង្វង់នោះ ថានឹងយកនគរយើង ។ ខ្ញុំបង្ហាញដុំដៃ ថាអញចង់វៃមួយកែង ។ ចិនបង្ហាញម្រាម៥ ថាមានគ្នាច្រើន ខ្ញុំបង្ហាញចង្អុលដៃមួយ ថាអញមានតែម្នាក់មិនខ្លាចទេ" លោកចៅហ្វាយឮដូច្នោះហើយក៏វិលទៅវិញ ។ ឯព្រះមហាក្សត្រក៏ចង់ដឹងអំពីប្រស្នានេះដែរ ។ **ធនញ្ជ័យ** ទូលព្រះអង្គថា "ចិនឱបដៃសួរថា ក្នុងទ្វីបទាំង៥នេះមានអ្វីខ្លះ? ។ ទូលព្រះបង្គំបត់ដុំដៃចង់ប្រាប់គេថា មានព្រះសិនេហកណ្តាល ទើបចិនបង្ហាញម្រាមទាំង៥ដណ្តឹងថា មានព្រះពុទ្ធ៥អង្គបានត្រាស់ក្នុងកប្បយើងនេះ ទើបទូលបង្គំបង្ហាញម្រាមដៃមួយប្រាប់ថា នៅមួយអង្គទៀតមិនទាន់បានត្រាស់នៅឡើយ ប្រស្នានេះគឺដូច្នេះឯង សូមទ្រង់ជ្រាប" ។



លោកគ្រូសង្ក្រាជ និងសម្តេចចៅហ្វាយទៅជួបនឹងព្រះមហាក្សត្រនិយាយតាមដំណើរដែល **ធនញ្ជ័យ** ឆ្លើយប្រាប់នោះឃើញថា ចម្លើយខុសគ្នាទាំងអស់មិន ប្រាកដថាជាប្រស្នាអ្វីឡើយ" ស្តេចនិងនាម៉ឺនរឹតតែខ្លាចប្រាជ្ញា **ធនញ្ជ័យ** ទ្វេឡើង ។

On the morning of the next day's contest, the Chinese scholars came to meet THUN CHEY again. The Chinese scholars made his arms like a circle. THUN CHEY reacted by flexing his muscles. Chinese scholars stretched his hand showing 5 fingers, whereas THUN CHEY showed one of his fingers. The monk chief watched the whole event but did not understand what THUN CHEY meant. So, he went to ask THUN CHEY to clarify the meanings of those riddles. THUN CHEY explained, 'When the Chinese scholar made his arms as a circle, I replied that it was an Angrut (a Cambodian fishing tool made from bamboo shaped like a round circle), and when I flexed my muscle to them, it meant that if there was an Angrut as a fishing tool, and how many fish did you catch? The Chinese scholar showed his five fingers meant that he could catch one fish which could be made into five pieces of dried fish. I showed my index to indicate that one piece of dried fish is eaten per day. After that, the monk chief went back to his monastery. Samdech Chaovai (Master) also wanted to know the meaning of the riddle. So, THUN CHEY explained, 'When the Chinese scholar made his arms as a circle, it indicated that they wished to take control of our Kingdom. I showed my flexing muscle to indicate that I would hit them. Then he showed his five fingers to signify that he had a lot of people, and I showed my index to signify that I was not afraid of them at all even though I was alone.' After understanding the meaning of the riddle, Samdech Chaovai (Master) went back home. The King also wanted to understand the meaning of the riddles. THUN CHEY pointed out, 'When the Chinese scholar made his arms like a circle, he wanted to ask, 'what are there in the five continents,' and I showed him my flexing muscle to tell him that there was Siddhārtha Gautama Buddha in the center. Then he continued to show his five fingers to signify that there were five enlightenment Buddha in our universe, and I showed my index to answer that there was another Buddha, who has not reached enlightenment yet.' 'The meanings are like that,' THUN CHEY told the King. The chief of monk and Samdech Chaovai (Master) came to meet the king and told him what they were told by THUN CHEY respectively. Then, they found out that what they had known about the riddle were different from each other that made them become more and more thoughtful of THUN CHEY's intelligence.

**ធនញ្ជ័យ** ទៅដល់ផ្ទះយកទឹកខ្មៅដាក់ក្តារ៤ជ្រុងក្រោមក្រដាសសនិងគម្ពីរហើយយកក្តាមជ្រលក់ទឹកខ្មៅឱ្យវារលើក្រដាស ។ ឯទឹកខ្មៅដែលជាប់នឹងជើងក្តាមបានជិតជាប់នឹងក្រដាសសហើយយកក្រដាសទៅហាលថ្ងៃ ។ លុះធ្វើដូច្នេះបានច្រើនហើយ ក៏យកគម្ពីរមករុំទុកទើបឱ្យកូនក្មេងមកអង្គុយជាច្រើន ហើយយកក្រដាសឱ្យក្មេងៗទន្ទេញផ្តេសផ្តាសឱ្យឮដូចគេរៀនអក្សរសាស្ត្រ ។ ដល់ព្រឹកឡើងអាចារ្យចិនចុះពីសំពៅមកផ្ទះ **ធនញ្ជ័យ** ប្រុងនឹងចោទប្រស្នាទៀត ។ **ធនញ្ជ័យ** ឃើញអាចារ្យមកដល់ហើយក៏ដើរទៅទទួលចាប់ដៃចូលមកអង្គុយលើកៅអី ហើយយកទឹកតែមកឱ្យអាចារ្យផឹក ។ ឯក្មេងៗទាំងនោះរៀនអក្សរឮកងរំពងស្តាប់ភាសាគ្នាមិនបាន ។ អាចារ្យចិនក៏ដើរមកមើលមិនស្គាល់ថា ជាអក្សរអ្វី ។



**ធនញ្ជ័យ** សួរអាចារ្យចិនថា "លោកអាចារ្យស្គាល់អក្សរនេះទេ?"។ អាចារ្យចិនឆ្លើយថា ទេ!។ ទើប **ធនញ្ជ័យ** ប្រាប់ថា "នេះគេហៅថា មីងឆ្វេងជាអក្សរព្រាហ្មណ៍ចាម បើមិនស្គាល់ឆ្លើយប្រស្នានឹងគ្នាមិនបានទេ អ្នកឯងចាញ់ខ្ញុំនឹងអក្សរនេះហើយ"។ អាចារ្យចិនក៏យល់ស្រប។ **ធនញ្ជ័យ** ព្រមានអាចារ្យចិនថា "បើចាញ់ហើយ ខ្ញុំយកតែរបស់និងសំពៅទាំង៤ ឯសំពៅមួយទៀតខ្ញុំឱ្យជិះត្រឡប់ទៅស្រុកវិញ។ ចំណែកនគរខ្ញុំថ្វាយស្តេចក្រុងចិនវិញចុះ តែចាប់ពីថ្ងៃនេះតទៅ បើឮឈ្មោះ **ធនញ្ជ័យ** ត្រូវតែខ្លាច"។ **ធនញ្ជ័យ** កាលបើបានរបស់អំពីសំពៅទាំងនោះហើយ ក៏ឱ្យគេជញ្ជូនរបស់ទៅថ្វាយស្តេចទាំងអស់មិនបានយកជារបស់ផ្ទាល់ខ្លួនឡើយ ។

THUN CHEY went to his home and put a square board under a piece of paper and a script. Then he dipped the crab legs into the ink and let those crabs creep over that piece of paper. The sheet was painted by the crabs' legs, and after that he dried out those sheets under the heat of the sun. Then he asked many kids to sit around and handed out the sheets to them and ordered them to pretend to read out loud whatever they wanted as if they had been reading literature. In the morning, the Chinese scholars left his junk and came towards THUN CHEY's house to challenge him again. THUN CHEY welcomed them, had them sit on chairs and offered them some tea. Meanwhile, the kids were reading loudly and it was impossible to understand what they were reading about. The Chinese scholars came to observe them, but they could not identify what kind of script it was. THUN CHEY questioned the Chinese scholars, 'Do you know this kind of script?' The Chinese scholars answered, 'No.' Then THUN CHEY told him, 'This is Mingchhveng, the Brahman script of Cham. If you don't know it, it means you lose because you are not able to identify this script. The Chinese scholars accepted the defeat. THUN CHEY warned the Chinese scholars, 'Now, you have lost but I will take only four of your junks and the properties on board. You can take back the remaining junk to use as transportation back to your Kingdom, and I will not take your Kingdom as our colony. But from today on, you should be scared whenever you hear my name.' THUN CHEY brought all the junks and the properties on board to the Khmer King. THUN CHEY did not take anything.



ព្រះមហាក្សត្របានដំណឹងថា **ធនញ្ជ័យ** ឈ្នះប្រស្នាអាចារ្យចិនដូច្នោះហើយក៏ត្រេកអរពន់ពេក ហើយទ្រង់មានព្រះបន្ទូលនឹង **ធនញ្ជ័យ** ថា ឱ្យរើសស្រីក្នុងវាំងធ្វើជាប្រពន្ធ ។ **ធនញ្ជ័យ** ក្រាបទូលស្ដេចថា "ទូលព្រះបង្គំមិនចង់បានប្រពន្ធនៅទីនេះទេ ឈ្មោះសុទ្ធតែញី" ស្ដេចទ្រង់សណ្ដាប់ហើយក៏មានព្រះបន្ទូលថា "ឯណាទៅឈ្មោះស្រីនោះ" ។ ទើប **ធនញ្ជ័យ** ទូលព្រះអង្គថា "ទូលបង្គំនឹងទៅរកស្រីនោះ តែសូមព្រះអង្គប្រទានសំពត់ ហូល ព្រែឱ្យច្រើននឹងទៅរកស្រីនោះឱ្យឃើញ" ។ ស្ដេចទ្រង់សណ្ដាប់ហើយក៏ព្រះរាជទានតាមសំណើ **ធនញ្ជ័យ** ។ លុះ **ធនញ្ជ័យ** ធ្វើដំណើរទៅដល់ភូមិមួយក៏ប្រទះនឹងនាង **សួស្ដី** ។ **ធនញ្ជ័យ** សួរនាងថា "សុំទោសនៅទីនេះតើមានស្រីដែរឬទេ?" ។ នាង **សួស្ដី** ស្ដាប់ហើយសួរវិញថា "ចុះស្រុកអ្នកឯងវិញមានប្រុសដែរឬទេ?" **ធនញ្ជ័យ** ស្ដាប់ហើយគិតថា "នេះហើយជាស្រី" ។ ទើប **ធនញ្ជ័យ** ប្រាប់ថា "ឯស្រុកខ្ញុំក៏មានប្រុសដែរ តើនាងដឹងដោយរបៀបណា?" ។ នាងឆ្លើយថា "ខ្ញុំដឹងព្រោះប្រុសនោះឈ្មោះ ជ័យច្រើនជាអ្នកធំ ជ័យឈ្នះអស់សត្រូវបានជាហៅថាប្រុស ចុះអ្នកវិញស្គាល់ស្រីដោយរបៀបណា?" ។ **ធនញ្ជ័យ** ឆ្លើយថា "ខ្ញុំស្គាល់ ! ត្បិតស្រីនោះឈ្មោះ **សួស្ដី** នឹងយកឈ្នះគ្មានគូប្រៀប" រួចពីនោះពួកគេក៏សាកសួរអំពីប្រវត្តិគ្នាទៅវិញទៅមក ។

Learning that THUN CHEY won the contest, the King was overjoyed, and he allowed THUN CHEY to choose a woman in the Royal Palace to be his wife. But THUN CHEY replied, 'I don't want to marry any woman here, as all of them are not ladies; they are only females.' 'Where can you find a lady?' the King asked. THUN CHEY replied, 'I am going to find that lady, but please kindly give me a number of silky cloth and sampots so that I can find that lady.' The King agreed to the request. When THUN CHEY arrived in a village, he met a lady named Soursdey. THUN CHEY asked, 'Excuse me, is there a lady in this village?' Soursdey replied, 'Is there a gentleman in your village?' THUN CHEY thought, 'She is a lady I am looking for.' Then, he replied, 'There is also a man in my village. How do you know about that?' She replied, 'I know that because the man named Chey is usually an important person, Chey wins all contests, so he is called a real man. And you, do you know a lady?' THUN CHEY answered, 'Yes, I do. The lady named Soursdey and she shall defeat all opponents incomparably.' Finally, they talked to each other about their backgrounds.



ឯ **ធនញ្ជ័យ** បានដឹងថានាង **សូស្ដី** គ្មានប្ដីដូច្នេះ ក៏ស្រាយសំពាយឱ្យម្ដាយឪពុកនាង **សូស្ដី** បានឃើញ។ ម្ដាយឪពុកនាង **សូស្ដី** ឃើញហូល ព្រែ ក៏ដើរមកមើលហើយសួរថា "អ្នកកូនយកសំពត់នេះទៅណា?"។ **ធនញ្ជ័យ** ជម្រាបថា "ខ្ញុំមករកប្រពន្ធ បើលោកទាំងពីរមេត្តាខ្ញុំ ខ្ញុំនឹងនៅបម្រើជាកូនក្នុងផ្ទះនេះ ខ្ញុំដងទឹក កាប់អុស បុកស្រូវ ខ្ញុំមិនខ្ជិលច្រអូសឡើយ។ ឪពុកម្ដាយ **សូស្ដី** និយាយគ្នាថា "អ្នកកំលោះនេះចង់បានកូនយើងហើយ មើលទៅឃើញថា គេជាកូនអ្នកមានពូជអម្បូរល្អណាស់"។ ម្ដាយឪពុក **សូស្ដី** ក៏បញ្ជាក់ទៀតថា "តើឯងចង់បានកូនខ្ញុំមែនឬ?"។ ទើប **ធនញ្ជ័យ** ជម្រាបថា "ក្នុងចិត្តខ្ញុំបាទចង់បាននាងណាស់"។ ឯម្ដាយឪពុកនាង **សូស្ដី** ថា "យើងឱ្យឯងហើយ ចូរឯងទៅរកមេអណ្ដើកមក។

**ធនញ្ជ័យ** ឮដូច្នោះហើយ ក៏ទៅរកអ្នកស្រុកភូមិធ្វើជាមេអណ្ដើកមកដណ្ដឹងនាង **សូស្ដី** មានក្មេងចាស់ជាច្រើនកាន់គ្រឿងបណ្ណាការឡើងទៅលើផ្ទះបំពាក់ចិញ្ចៀនកូនក្រមុំ និងកំណត់ថ្ងៃរៀបការ។ បន្ទាប់ពី **ធនញ្ជ័យ** បានរៀបការជាមួយនាង **សូស្ដី** ហើយ **ធនញ្ជ័យ** ក៏ធ្វើជាលាប្រពន្ធ និងឪពុកម្ដាយក្មេកទៅទារប្រាក់ដែលនាហ្មឺនជំពាក់។

When THUN CHEY was aware that Soursdey was still single, he unfastened his pack so as to show Soursdey's parents. Seeing the silky cloth and a lot of sampots, Soursdey's parents came to ask, 'Where are you taking this silk cloth to?' THUN CHEY replied, 'I am looking for a lady as my wife. If you kindly permit, I will stay here serving you as your son in your family. I will carry the water, prepare the fire wood, pound the rice, and I will never be lazy at all.' Soursdey's parents talked to each other, Perhaps this man loves our daughter and he must be from a very good family.' Soursdey's parents asked more questions, 'Do you want to marry my daughter?' THUN CHEY replied, 'Yes, I do. I love her with all my heart.' Soursdey's parents said, 'I agreed, but you have to find a go between.' THUN CHEY asked the villagers to be his go- between to ask for Soursdey's hands. There were many young and old people carrying the jewels to the house to attend the engagement, and a wedding date was set. After marriage, THUN CHEY left his wife and his parents-in-law to collect debts from some royal officials who owed him.

**ធនញ្ជ័យ** ទៅដល់សាលាជួបជុំអស់នាហ្មឺនធំតូចនិយាយថា "អស់លោកហ៊ានភ្នាល់នឹងខ្ញុំទេ ខ្ញុំអាចប្រើស្ដេចបាន"។ អស់នាហ្មឺនឆ្លើយថា "អើ ! បើឯងប្រើស្ដេចបានមែនអញនឹងឱ្យប្រាក់ឯងចុះ"។ ពួកនាហ្មឺនក៏យករឿងនេះទៅទូលស្ដេច ។ ឯព្រះមហាក្សត្រខ្ញាល់នឹង **ធនញ្ជ័យ** មាកងាយនេះណាស់ ក៏ហៅ **ធនញ្ជ័យ** មកមានព្រះបន្ទូលសួរថា "អាជ័យ ! ឯងនិយាយថាប្រើអញមែនទេ?" ។ **ធនញ្ជ័យ** ទូលថា "ព្រះករុណាវិសេសប្រើមិនទាន់បានទេ លុះត្រាតែព្រះអង្គបែរព្រះភ័ក្ត្រទៅក្រោយសិន ក្រាបទូល" ស្ដេចទ្រង់សណ្ដាប់ហើយក៏បែរព្រះភ័ក្ត្រទៅក្រោយមែន ។ **ធនញ្ជ័យ** ទូលព្រះអង្គថា "នេះហើយហៅថាប្រើ សូមទ្រង់ជ្រាប"។ ស្ដេចសណ្ដាប់ហើយក៏មានព្រះទ័យខ្ញាល់នឹង **ធនញ្ជ័យ** ណាស់ ។ ឯ **ធនញ្ជ័យ** ក៏ទៅទារប្រាក់ពីនាហ្មឺនទាំងអស់នោះយកទៅឱ្យប្រពន្ធ ។ អស់នាម៉ឺនខឹងនឹង **ធនញ្ជ័យ** ពេក ក៏ញុះញង់ស្ដេចបណ្ដេញ **ធនញ្ជ័យ** ឱ្យចុះសំពៅទៅស្រុកចិនត្បិតស្រុកនោះធំ ហើយពួកគេស្អប់វាណាស់ គេនឹងសម្លាប់វាចោល ។ ព្រះមហាក្សត្រស្ដាប់ហើយក៏ហៅ **ធនញ្ជ័យ** មកប្រាប់ថា "អាជ័យ ! យើងឱ្យឯងទៅនៅស្រុកចិន ត្បិតស្រុកនោះធំណាស់ ឯងនៅស្រុកខ្មែរទៀតមិនបានទេ" ។ **ធនញ្ជ័យ** ក៏ទៅនៅស្រុកចិនតាមព្រះបន្ទូលស្ដេច ។

THUN CHEY arrived at the Royal Hall meeting all the royal officials and talked to them, 'Do you all want to bet with me? I can command the King to do something.' All royal officials surprised, 'Really? If you can, I will give you some money.' Then, those royal officials went to inform the King about that. The King became furious and asked THUN CHEY to see him, 'Chey, did you say that you could command me to do something?' THUN CHEY replied, 'Your Majesty, now I have not been able to command you yet unless you turn your face around.' The King turned his face around as THUN CHEY commanded. Then, THUN CHEY said, 'Your Majesty, this is what we call "order".' After hearing that, the King was very angry.THUN CHEY collected money from those royal officials and gave it to his wife. Because of the anger they had with THUN CHEY, the royal officials convinced the King to exile THUN CHEY by making him travel by junk to China.



They knew that China was very a big country and all Chinese people hated him so much, and they would kill him. After the King was convinced, he told THUN CHEY, 'Chey, I want you to live in China because that Kingdom is very big and you cannot live in the Khmer Empire any more.' THUN CHEY followed the King's order.



កាល **ធនញ្ជ័យ** ជិះសំពៅទៅដល់ស្រុកចិនហើយ  ក៏ផ្តាំអស់អ្នកសំពៅដែលវិលមកស្រុកខ្មែរវិញថា "សូមផ្តាំទៅប្រពន្ធខ្ញុំផង ខ្ញុំនឹងវិលទៅវិញបន្ទាប់ពី៧ខែក្រោយ"។ នៅស្រុក ចិន **ធនញ្ជ័យ** បានទៅធ្វើការស៊ីឈ្នួលឱ្យនាហ្មឺនធំម្នាក់ ។

លុះ **ធនញ្ជ័យ** សន្សំបានប្រាក់ច្រើនហើយ ក៏ទិញអង្កររួចធ្វើនំបញ្ចុកលក់ឱ្យពួកចិនហូប ។ កាលនោះស្រុកចិនមិនទាន់ចេះធ្វើនំនេះទេ ដល់ឃើញ **ធនញ្ជ័យ** ធ្វើដូច្នោះក៏បបួលគ្នាមកទិញនំពិសា ។ បន្ទាប់មកពួកគេនិយាយគ្នាថា អ្នកនេះធ្វើនំឆ្ងាញ់ណាស់ការលក់នំឆ្ងាញ់បែបនេះ ក៏និយាយតៗគ្នាបានល្បីទៅដល់ស្ដេចក្រុងចិន ។ ទ្រង់ក៏ឱ្យសេនាហៅ **ធនញ្ជ័យ** មកមានព្រះបន្ទូលថា "នំឯងអីក៏វែងៗម្ល៉េះ? មានឈ្មោះថានំអីទៅ?" ។ **ធនញ្ជ័យ** ទូលតបថា "នេះគេហៅថានំបញ្ចុក បើទ្រង់ចង់សោយ ទាល់តែងើយឡើងលើ ហាមាត់ឱ្យធំ លើកដៃឱ្យខ្ពស់ទើបឆ្ងាញ់ពិសា" ។ ស្ដេចចិនឮដូច្នោះក៏យកនំនោះមកសោយ ហើយងើយដូចពាក្យ **ធនញ្ជ័យ** ទូលប្រាប់ ។ **ធនញ្ជ័យ** ឃើញដូច្នេះក៏សើចចំអកឱ្យស្ដេចថា "មើលមុខស្ដេចចិនមុខខ្មៅអែ មើលមុខស្ដេចខ្មែរដូចខែពេញបូណ៌មី" ។ ស្ដេចក្រុងចិនឮ **ធនញ្ជ័យ** ដៀលដូច្នោះ ទ្រង់ក៏ព្រះក្រោធយ៉ាងខ្លាំង ហើយត្រាស់ឱ្យអស់អាមាត្យចាប់ **ធនញ្ជ័យ** ដាក់គុកសំរឹទ្ធិ ។ ក្នុងគុកនោះត្រជាក់ណាស់ បើមនុស្សណាចូលទៅហើយកម្រនឹងរស់ឡើយ ។

As soon as THUN CHEY arrived in China, he sent a message through a junk owner, 'Please, tell my wife I will come back in the next 7 months.' THUN CHEY worked as a servant of a Chinese mandarin. When he saved enough money, he bought rice to make Num Banh Chok (Cambodian traditional noodle) and gave it to Chinese people it. At that time, Chinese people did not how to make noodle yet. So, when they saw THUN CHEY's noodle, they bought to eat. Then they said that THUN CHEY's noodle was really delicious. This information reached the King of China. The King commanded his royal servants to bring THUN CHEY to him and asked, 'Your noodle is very long. What is it called?' THUN CHEY replied, 'It is called Num Banh Chok. If you want to eat it, you have to raise your head up, open your mouth broadly, and use your hand to lift the noodle highly so that you can eat it deliciously.' The King followed THUN CHEY's advice. Seeing that, THUN CHEY mocked at the King, 'Chinese King's face is so black, whereas Khmer King's face is like a full moon.' Hearing that, the King of China became so furious that he made a command to his servants to imprison THUN CHEY into a bronze cell. That cell was very cold and whoever was imprisoned there would hardly survive.

**ធនញ្ជ័យ** រស់នៅក្នុងគុកជាមួយជនជាតិចិនម្នាក់ ។ **ធនញ្ជ័យ** រងាខ្លាំងពេកក៏បបួលចិនបោកចំបាប់ឱ្យក្ដៅសាច់បែកញើសនឹងបានស្រួលខ្លួន។ លុះបានពីរ-បីថ្ងៃ អស់នាម៉ឺនទៅមើលឃើញអ្នកទោសមិនទាន់ស្លាប់ក៏ហើទៅ ។ **ធនញ្ជ័យ** ក៏ធ្វើខ្លែងឯកបង្ហោះរាល់យប់ ។ ស្ដេចឮសូរសំឡេងប្លែកក៏ឆ្ងល់ក្នុងព្រះទ័យថា "សត្វនេះយំតែពេលយប់ មិនដែលឮពេលថ្ងៃទាល់តែសោះ ទើបហៅហោរមកគន់គូរ តើសំឡេងនេះជាសំឡេងសត្វអ្វី?" ។ ហោរទូលព្រះអង្គថា "បានជាសត្វនេះយំដូច្នោះ ត្បិតកើតហេតុក្នុងនគរ បើរកឧត្បាតនេះមិនឃើញទេ សត្វនោះនឹងស៊ីមនុស្សក្នុងព្រះនគរនេះមិនខានឡើយ" ។ ស្ដេចព្រះសណ្ដាប់ហើយមានព្រះបន្ទូលថា "បើដូច្នោះ តើឧត្បាតព្រោះអ្វី" ។ ទើបហោរទូលថា "ទូលព្រះបង្គំឃើញថា មានគេយកអ្នកប្រាជ្ញស្រុកខ្មែរមកប្រោស





ចោលក្នុងស្រុកយើង ឥឡូវនេះគេនៅក្នុងគុកសិរីទ្ធិឯណោះ មានតែឱ្យគេទៅស្រុកវិញទេ ទើបល្អ"។ ឯព្រះមហាក្សត្រក្រុងចិនក៏បញ្ជូន **ធនញ្ជ័យ** ទៅស្រុកខ្មែរវិញ"។ ព្រះមហាក្សត្រខ្មែរឮថា **ធនញ្ជ័យ** វិលមកវិញក៏ខ្លាចប្រាជ្ញា **ធនញ្ជ័យ** មិនហ៊ានធ្វើសេចក្ដីឱ្យទាស់ចិត្តឡើយ។

THUN CHEY stayed in the cell with another Chinese prisoner. Being very cold, THUN CHEY wheedled that man to do wrestling with each other until they sweated and their body got warm. Several days later, the guards saw the prisoners still alive, but they just ignored. THUN CHEY made a kite with very strange sound and flied it every night. Hearing the strange sound, the Chinese King wondered why this kind of creature wept only at the night and never at the daytime. So, he called the royal astrologer to interpret the sound of the kite. The astrologer interpreted, 'The creature weeps means that bad something will happen in our Kingdom. If we cannot find it, it will eat all people in our country.' The King continued to question, 'Why dose this creature weep?' Astrologer replied, 'I see that there is a Khmer sage who is living in exile in our Kingdom and now he is in prison. Send him back to his own Kingdom is a good solution.' After THUN CHEY was sent back to the Khmer Empire, the Khmer King really appreciated THUN CHEY's intelligence, and from then on the King did not dare to cause any troubles to harm THUN CHEY.



លុះក្រោយមក **ធនញ្ជ័យ** ក៏មានជំងឺជាទម្ងន់ ដោយអស់សង្ឃឹមក្នុងការព្យាបាល **ធនញ្ជ័យ** ក៏បានផ្តាំប្រពន្ធថា "ពេលបងស្លាប់ទៅ សូមយកបងទៅកប់ ហើយដោតចំរូងស្រួចៗនៅលើផ្នូរបងកុំខាន ហើយទៅទូលហ្លួងផង ថាបងឈឺជិតស្លាប់ហើយ"។ ឯនាង **សូស្តី** ក៏ទៅទូលហ្លួងតាមបណ្តាំ **ធនញ្ជ័យ**។ ស្តេចដឹងដូច្នេះហើយក៏យាងទៅសួរសុខទុក្ខ **ធនញ្ជ័យ**។ **ធនញ្ជ័យ**ទូលព្រះអង្គថា "បើសោយត្រីព្រួលកុំចោលស្រកា បើសោយត្រីប្រាកុំចោលស្រកី បើស្លក្បាលត្រីប្រានឹងម្ជូរសណ្តាន់" ។ កាលបើ **ធនញ្ជ័យ** ស្លាប់ទៅហើយ គេក៏យកខ្មោច **ធនញ្ជ័យ** ទៅកប់ហើយធ្វើចំរូងដោតលើផ្នូរនោះតាមបណ្តាំរបស់គេ ។ អស់មនុស្សក្នុងរាជវាំងដែលស្អប់ **ធនញ្ជ័យ** ក៏ប្រើមនុស្សឱ្យទៅជុះអាចម៍ដាក់ផ្នូរ **ធនញ្ជ័យ** ។ នៅពេលពួកគេដាក់គូទជុះក៏ស្រាប់តែមានចំរូងមុតគូទពួកគេ ហើយក៏រៀងមិនហ៊ានមកទីនេះទៀតឡើយ ។ ពួកគេនិយាយគ្នាថា "ពិតជាអ្នកប្រាជ្ញមានបញ្ញាមែន គាត់ស្លាប់បាត់ទៅហើយ គ្រាន់តែជុះអាចម៍ដាក់លើផ្នូរគាត់ផងក៏មិនបានដែរ ។ **ចប់**

The time went by, THUN CHEY had a serious illness and it could not be cured. THUN CHEY left a few words to his wife, 'Remember that after I die, you have to grow some sharp stakes on my tomb and go to inform the King that I am dying.' Soursdey followed THUN CHEY's advice. Learning that THUN CHEY was dying, the King visited him. THUN CHEY told the King, 'If you eat Trey Proul (cirrhinus auratus), please don't leave its scales, if you eat Trey Bra (iridescent shark-catfish), don't leave its gills and if you cook the head of Trey Bra sour soup, don't forget to put Sandan (a kind of sour plant, usually its leaves are used to cook).' After THUN CHEY died, his body was buried and sharp stakes were put up on his tomb. Those who hated THUN CHEY asked other people to defecate on THUN CHEY's tomb. When they sat down to defecate their buttocks were stabbed by the stakes. From then on, they never dared to go to THUN CHEY's tomb again. People said, 'He is really a wise man. Although he died, no one can defecate on his tomb.' **THE END**